« Sakountala » — Reçu le 20...
INDOCHINE FRANÇAISE RÉGIE DU DÉPÔT LÉGAL

រ៉ាយ-ប៊ុត

# សកុន្តលា

ARCHIVES NATIONALES 86
CÔTE B-104-1201
B-12
D-86
N° 64
...ជាតិ
171



ព.ស. ២៤៩៥ គ.ស. ១៩៥២

# សកុន្តលា

លោកអបនិន្ទ្រណាត្ថ តាគរ អ្នកនិពន្ធជាភាសាបឹងកាល់

លោក ត. ម. ឆត្តេរជិ និងលោកស្រី អង់ជ្រេ-ការបឺលែស

ជាអ្នកប្រែពីភាសាបឹងកាល់មក ជាភាសាបារាំង

លោក រ៉ាយ-ប៊ុក ជាអ្នកប្រែពីភាសាបារាំង មកជាភាសាខ្មែរ ។

# SAKOUNTALA

par

Abanindranath Tagore

adapté du bengali par

Andrée Karpelès et T. M. Chatterji

**Traduit du Français en Cambodgien**

par

**RAY-BUC**

# អារម្ភកថា

សកុន្តលាគឺជាបុគ្គលិកា ក្នុងរឿងរបាំកលីទសះដែលមាននាមល្បីល្បាញផងគេនៅប្រទេសឥណ្ឌា ក្នុងសតវត្សទី៤ទី៦ ។ លោកកលីទសះនេះមានកិត្តិសព្ទប្រហែលនឹងលោកស្ហេកស្ពៀរ (Shakespeare), ពាក្យអង់គ្លេសថាសិកស្ពិរ) ខាងប្រទេសអង់គ្លេស, លោកម៉ូលីយែរ (Molière) ខាងប្រទេសបារាំង ។

សៀវភៅនេះមានអ្នកបកប្រែជាច្រើន ពីសតវត្ស១១ (គ.ស.) មានលោកប្រ៊ុយញែរ (Brugnère) បកប្រែចេញពីសៀវភៅភាសាអង់គ្លេសរបស់លោកវិលិយាំសូន្ស (William-Jones), តមកមានអ្នកបកប្រែឯទៀតគឺលោកហ្វូច (Fauche), ហ្វ៊ូកូ (Foucaux) អាបែលបែរកែញ (Abel Bergaigne), ប៉ូលឡឺហ៊ុស៊ឺរ (Paul Lehugeur) ។

នៅ គ. ស. ១៩១៤ លោកម៉ូរិស-ប៉ូតឺសែរ (Maurice Pottecher) បានយករឿងទៅរចនាជាពាក្យកាព្យនាមថា “ព្រះទម្រង់ព្រះនាងសកុន្តលា” សម្រាប់យកទៅលេងល្ខោននៅតំបន់ប៊ុស្សង់ (Bussang) ។ លំដាប់តមក, លោកស៊ិលវ៉ែង-ឡេវី (Sylvain Lévi) បានបកប្រែសម្រាប់បង្រៀនពួកនិស្សិតនៅសាលាឧត្តមសិក្សា ។

បើតាមពិនិត្យឲ្យហ្មត់ចត់ លោកអបទិទ្រុណ័តគាគរ ជាបណ្ឌិតអក្សរ

សាស្ត្រឥណ្ឌៀបានតែងរឿងសកុន្តលានេះជាភាសាប័ង្គាលី ដោយដកស្រង់យកពីសៀវភៅសំខាន់នៃបណ្ឌិតគលីទស: ។ លំដាប់តមក លោកស្រីអង់ទ្រេ ការប៉ឺលេះ (Andrée Karpelès) នឹងលោក ត.ម.ចាត្តរជិ (T.M. Chatterji) បានបកប្រែជាភាសាបារាំង លោក ហ៊យ-ប៊ុក បកប្រែពីភាសាបារាំងមកជាភាសាខ្មែរ ។

“ សកុន្តលា ” ជារឿងប្រលោមលោកតែមានរឹទ្ធតាបសបួលមកលាយលំផង, ខ្ញុំបានព្យាយាមបកប្រែសៀវភៅនេះ មានកន្លែងខ្លះខ្ញុំបានតែងជាពាក្យកាព្យបញ្ចូលដើម្បីនឹងរចនារឿងនេះឲ្យមានលំអរឬសម្រស់ដ៏ថ្លៃថ្លា សម្រាប់លោកអ្នកអានៗកំសាន្តសប្បាយគ្រាន់តែអផ្សុកមួយពេលមួយកាលតែគង់មានខុសអក្ខរៈឬព្យញ្ជនៈខ្លះមិនខាន, ត្រង់ខនេះខ្ញុំសូមឲ្យលោកអ្នកអានជួយកែឲ្យបានត្រិមត្រូវផងចុះ ខ្ញុំសូមអរគុណលោកជាមុនៗ

បើទុកជាយ៉ាងណាក៏ដោយ, សៀវភៅនេះខ្ញុំបកប្រែបំណងឲ្យបានចម្រើនខាងអក្សរសាស្ត្រខ្មែរ, ឲ្យជនជាតិខ្មែរព្យាយាមអានសៀវភៅឲ្យកាន់តែច្រើនៗឡើងដើម្បីនឹងរចនាខ្មែរ ឲ្យទៅជាអ្នកចេះដឹងមានប្រាជ្ញាគ្រប់ៗគ្នាឡើង, ជាបណ្ឌិត ប្រទេសណាមានបណ្ឌិតច្រើនប្រទេសនោះនឹងបានឡើងទៅកាន់វឌ្ឍនធម៌ក្នុងកាលជាអនាគត ព្រមទាំងឯករាជ្យជាទី

ពេញចិត្តរបស់យើងទាំងអស់នេះ សូមសេចក្ដីព្យាយាមរបស់ខ្ញុំជាកុសលផ្សាយចែកជូនទៅមាតុភូមិកម្ពុជា ជាទីស្រឡាញ់របស់ខ្ញុំហួសជីវិត ឲ្យគាត់ធ្វងនូវឧបស័គ្គគ្រប់យ៉ាង រហូតដល់ពាមពោលគឺឯករាជ្យដោយសម្បូណ៌ភាព ។

ភ្នំពេញនៅថ្ងៃទី ១៩ មិថុនា ១៩៥២

ក៉ាយ - ប៊ុតា

# អាស្រមនៃឫសី ភាគទី ៣

ពីអតីតកាល មានព្រៃមួយធំ នៅក្នុងព្រៃនោះ មានដើមពោធិ៍មួយធំត្រសុំសាខានិងតាលព្រឹក្សដុះជាជួរហែ ហើយនិងបន្ទាស្អិត; នៅទីនោះមានភ្នំតូច ៗ ជាច្រើនហើយមានភ្នំធំមួយ ៗ ក្រៅពីនេះ នៅមានស្ទឹងមួយតូច ហៅថា មលិនី, ទឹកស្ទឹងមលិនី, ស្ងប់ស្ងាត់ថ្លាត្រយង់ ហើយភ្លឺដូចកញ្ចក់ ៗ រុក្ខជាតិ. មេឃខៀវ ពពកសុវណ្ណពណ៌ បក្សាដែលកំពុងហើរពោលស្រមោលចាំងទៅក្នុងទឹកស្ទឹងមលិនី ឃើញច្បាស់ដូចឆ្លុះកញ្ចក់ ... គេបានឃើញអ្វីផ្សេងពីនេះទៀត ក្នុងទឹកស្ទឹងមលិនីនេះ គេឃើញស្រមោលខ្នុមជាច្រើន ដែលសន់នៅក្រោមគល់រុក្ខជាតិ ៗ.

⁘

នៅក្នុងព្រៃនោះ តាមមាត់ស្ទឹង មានមនុស្សនិងសត្វតិរច្ឆានរស់នៅជាមួយគ្នាដោយសុខដុមរមនា ៗ

មានបក្សាក្ងាននិងកុកជាច្រើនហើរចុះនៅតាមមាត់ស្ទឹង. មានសកុណសត្វតូច ៗ ហើយនិងហ្វូងសេកជាច្រើនសម្បុរខៀវយំនៅមែកឈើ ហើយធ្វើសំបុកនៅប្រហោងឈើទាំងនោះ ៗ ក្នុងចន្លោះនៃព្រៃ, លើស្មៅខៀវខ្ចី និងក្នុងស្រែមានសត្វប្រើស រមាំងរត់ដេញគ្នាលេង ៗ

នៅនិទាឃៈរដូវ. មានតាវ៉ៅ "កុគីលស៍(១)" យំតាំងពីបុព្វណ្ហសម័យហើយដល់សរទៈរដូវ គេបានឮក្ងោកយំពង់ស្លាប ៗ

នៅគល់ពោធិ៍មួយធំ (ប្រហែលអាយុពីពាន់ឆ្នាំ) កាមទេពតាបសមានសក់ក្រងដូចកន្ទេល, បានធ្វើអាស្រមមួយនៅទីនោះ. តាបសនោះរស់នៅជាមួយនឹងភរិយាឈ្មោះនាងគោតមី ក្នុងខ្ទមធ្វើពីមែករុក្ខជាតិ ហើយស្លៀកពាក់ទាំងពីរនាក់នូវសម្បកឈើ ៗ នៅក្នុងក្រោល, មានគោញីខ្មៅនឹងកូនគោជាច្រើន. តាបសនេះគាត់មានអ្នកជិតខាងទៀតគឺឫស្សីក្មេង ៗ ជាសាវកនៃតាបស ស្លៀកពាក់សំបកឈើដូចគ្នា ៗ

តើពួកឫសីក្មេងនោះធ្វើអ្វី ?

ពេលព្រឹក. ពួកឫសីបានអាននូវរឿងរ៉ាវដែលមានក្នុងសន្ធគម្ពីរ, មានតាបសកាមទេពជាគ្រូអាចារ្យ. រួចមក, លោកបានបូជាចំពោះព្រះអាទិទេពនូវបុប្ផាគ្រប់យ៉ាងដែលដុះក្នុងព្រៃ; បើមានភ្ញៀវមក, តាបសទទួលឲ្យសំណាក់នៅអាស្រមរបស់គាត់ហើយគាត់ទៅបេះផ្លែឈើ. ដែលមានឱជារសនៅក្នុងព្រៃ ៗ

តើសាវកក្មេងរបស់តាបសនោះធ្វើដទៀត ?

ពួកសាវកក្មេងនោះត្រាច់ទៅលេងមួយគូ ៗ ក្នុងព្រៃ ហើយសន្ទនាគ្នាទៅ

---

(១) កុគីលស៍; តាវ៉ៅ នៅប្រទេសឥណ្ឌៀ ។

វិញទៅមករើសអុសដើម្បីនឹងយកមកដុតបន្ថែមត ៗ គ្នានៅបូជនីយដ្ឋានព្រះអគ្គី. ឬធ្វើជានាយគោបាលនាំគោញីទៅទឹងនឹងកូនគោសទៅឲ្យស៊ីស្មៅឯវាល; ឬនគាលធ្វើ, ដូចជាទារក. អ្នកទាំងនេះនាំគ្នាលេងសប្បាយក្រោមម្លប់ឈើធំ: ឬនគាលសង់គេហដ្ឋាននៅលើដីខ្សាច់," ឬធ្វើវត្ថុសម្រាប់ក្មេងលេងឬបក្សាទឹងដីឥដ្ឋ. កាត់ឫស្សីធ្វើខ្លុយ ធ្វើទូកតូច ៗ នឹងស្លឹកពោធិ៍ ៗ

មានក្មេងកំនឹងប្រើសច្រើន មកនៅលេងជាមួយអ្នកទាំងនោះ ៗ ហើយកាលណាសាវកទាំងនោះឈប់លេងល្បែងផ្សេង ៗ បានទៅពណ៌-នាម្ចាត់ម្ពង់, នូវរឿងពីរសង្គ្រាមពួកទេវតានឹងការស្រុករកំសូត្រធម៌ជាបទបែបដែលលោកគ្រូកាមទេពបានបង្រៀនគ្រប់គ្នា ៗ

ពិតមែនតែសេចក្ដីសុខនៅក្នុងព្រៃនោះមានជានិរន្តរកាល, លោកកាមទេពនឹងនាងគោតមីជាភរិយា នៅតែព្រួយវិតក្កពន់ពេក, នៅខ្វះអ្វី? អ្នកទាំងពីរលែងបានជួបនឹងរតនវត្ថុដែលគ្មានអ្វីអាចផ្ទួរផ្ទាបាន, ដុំពេជ្រដែលធ្វើឲ្យខ្ទមនេះមានរស្មីភ្លឺស្វាងរង់រឿងពីដើម, ឥឡូវបាត់រកពុំឃើញ អ្នកទាំងពីរដែលបានឃើញនូវពន្លឺតូចដែលបំភ្លឺទីងងឹតអន្ធការ. នាងដែលអ្នកទាំងពីរទុកជាអណ្ដាតភ្លើងដែលកំដៅជីវិតាពរបស់ខ្លួន. នាង

ចាកចេញទៅប្រទេសឆ្ងាយ. អ្នកទាំងពីរបាត់នាងសកុន្តលាដែលជាទីពេញចិត្ត ។

តែនាងណាដែលមាននាមថាសកុន្តលា? នាងទារិកាមួយៈ

តើមានព្រឹត្តិការណ៍យ៉ាងណា ? ហេតុម្ដេចក៏នាងបាត់ពីទីនេះទៅ ?

ដើម្បីនឹងឲ្យដឹងនូវរឿងរ៉ាវនេះសព្វគ្រប់ៈ ត្រូវពិនិត្យពីអតីតកាលយូរមកហើយ ។

ពីដើមនៅក្នុងព្រៃស្ថិតជុំវិញអាស្រម, ហើយពេលយប់ងងឹតគ្មានព្រះចន្ទ្រ មានក្មេងស្រីម្នាក់ទើបនឹងបដិសន្ធិ (ស្អាតសមរម្យដូចល្អិតូចមួយមានសម្ផស្សគួរជាទីពេញចិត្ត) មាតានាមនាងទេវធិតាមេណកាបានបោះបង់ចោលនៅទីនោះៈ នាងជាមាតាបានទុកចោលនាងទារិកានៅលើស្មៅ. ក៏គេៀសខ្លួនចេញបាត់ទៅ ។ ក្នុងពេលនោះ; បក្សាទាំងអស់បានមកជួយថែទាំនាងទារិកាដោយត្របាំងស្លាបគ្របកុំឲ្យថ្ងៃក្ដៅ ហើយក្រាបជិតនាងអប់កំដៅនឹងដើមទ្រូងវាមានរោមជាច្រើន ។

នាងមេណកាជាមាតាមានចិត្តរឹងដូចថ្ម បានបោះបង់កូនខ្លួនចោល, តែបក្សាទាំងឡាយនៅក្នុងព្រៃមានសភាវគតិ អាណិតអាសូរដល់នាងតន់ពេក, បានមកបីបាច់ថែរក្សានាងដោយមេត្តាករុណា,

នៅបុព្វណ្ហសម័យ, ពួកឫសីក្មេងជាច្រើនបានត្រាច់ទៅក្នុងព្រៃ បេះផ្លែឈើយកមកបូជា, ស្រាប់តែបានឃើញនូវគុម្ពោតមួយ ឮសូរស្លាបបក្សាហើរចុះឡើង ៗ

ពួកឫសីនេះបានចូលជិតគុម្ពោតនោះ បានជួបប្រទះនឹងនាងទារិកា សកុន្តលា ហើយក៏រើសយកនាងដាក់ក្នុងល្អីជាមួយ នឹងផ្លែស្លឹកឈើ ហើយក៏យកទៅជូនលោកគ្រូកាឞទេព ៗ

បក្សាទាំងអស់ក្នុងព្រៃ, ប្រើសទាំងអស់ចង់ហែហមនាងសកុន្តលា ទៅជាមួយផង, ក៏បានដើរតាមពួកឫសីក្មេងរហូតដល់អាស្រម, ពួកសត្វទាំងនេះ ក៏ស្ថិតនៅជិតអាស្រមនោះ ហើយក៏លែងទៅណាមកណាឆ្ងាយពីនាងទៀត ៗ

នាងសកុន្តលា បានរស់នៅឯអាស្រម, មានមាតាចិញ្ចឹមនាង គោតមី បីបមថ្នមជានិច្ច ៗ. តមកទៀត, នាងវារលើដីខ្ជម. រួច. រត់ចេញមកក្រៅ. មកលេងក្រោមម្លប់ពោធិ៍ ៗ

## កុម្ពោតមនោរម្យ

នាងសកុន្តលាចម្រើនវ័យវឌ្ឍនាការឡើង, នាងសកុន្តលា មានរូបឆោមលោមពណ៌ កាន់តែស្អាតល្អតាមលំដាប់.....តមក, នាងមាន

អាយុល្មមឲ្យមានស្វាមី ។ លោកគ្រូកាមទេព បានចាកចេញអាស្រម ត្រាច់សព្វដែនដី ដើម្បីនឹងស្វែងរកស្វាមីឲ្យសមរម្យនឹងនាង ។

បិតាមាតាបង្កើតនាងសកុន្តលា បានបោះបង់នាង តែនាងពឹងពាក់លើលោកគ្រូកាមទេព និងនាងគោតមី បិតាមាតាចិញ្ចឹមនាង ដែលមានចិត្តអាណិតអាសូរចំពោះនាងជាខ្លាំង; នាងមិនមានបងប្អូនប្រុសទេ តែពួកសាវកក្មេងៗទាំងប៉ុន្មាន ទុកនាងដូចជាប្អូនស្រី ហើយវក្ខាល–គារស៊ី និងបុប្ផាក្នុងព្រៃទុកនាងដូចបងប្អូនជិតស្និទ្ធដូចនោះ ។

នាងសកុន្តលា មានមិត្តពីរនាក់ស្រឡាញ់រាប់អានគ្នា, ដោយស្មោះស្ម័គ្រជាបំផុត គឺនាងអនសូយា និងនាងប្រិយម្ពទា; នាងមានមិត្តមួយ គឺកូនប្រើសញីដែលលេងកំសាន្តជាមួយនាងជានិរន្តរកាល ។

នាងទារិកាទាំងបីនាក់មានកិច្ចរវល់ជាខ្លាំង គឺការដាំបាយធ្វើម្ហូបអាហារ, ទទួលភ្ញៀវដែលមកលេងអាស្រម. ស្រោចវក្ខជាតិព្រឹកល្ងាច; ជួនកាលនាងចូលចិត្តក្រងបុប្ផាតូចៗ នៃផ្កាម្លិះទៅនឹងត្រយស្វាយ ។

នាងអនសូយានិងនាងប្រិយម្ពទាទាំងពីរនាក់ មានកិច្ចផ្សេងពីនេះទៀតគឺ: រាល់ព្រឹក, នាងបានស្រោចទឹកកូនឈើផ្កាហៅថាមទោបិស៍ (១) ហើយនាងបានស្មូត្រសច្ចាធិដ្ឋានថា ៖

(១) មទោបិស៍ (Madobis) : វក្ខជាតិមានផ្កាស ហើយក្រអូប ។

"កាលណាឈើ មនោបិស៍ មានបុប្ផា
សូមសត្វា សកុន្តលា មានស្វាមី
មានយានធំ ជិះនាំដ៏ពីរ កាបសួស្ដី
សមស្រស់ស្រី ឆាដ៏ស្រើបស្រួល សប្បាយត្រាណា ៗ
មនោបិស៍ សូមឲ្យអ្នក ចេញបុប្ផា
ស្រាបកាយា ក្រអូបឈ្ងុយ ឈ្ងប់កល្យាណា
សកុន្តលា ប្អូនស្រីយើង រាសជាថាន
ចិត្តក្សេមក្សាន្ត កាបម្លូរក្សេ សន្តិសុខ ៗ

*តើនាងទារិកាតាំងពីធ្វើអ្វីទៀត, នៅក្នុងព្រៃនេះ ?*

*នាងតាំងពីរត់លេងសប្បាយ, ពាសពេញព្រៃ, គ្មានខ្លាចគ្មានអ្នកណាហាមឃាត់, ដោយសារដូចជាកូនប្រើសក្នុងព្រៃ, នាងជជែកគ្នាហើយក្រេបរសជាតិ ពីកំសួលដែលផ្សាយចេញពីគុម្ពោតព្រៃសប្បាយជាយ៉ាងក្រៃលែង ដូចជាភមរធំ ៗ ហើរប្រវាត់ពាសពេញព្រៃផ្ចាក់កេសរផ្កាពល់ល្ងាច នាងទៅឯគង្គាត្រជាក់នៃស្ទឹង មលិនី ហែលលេងសប្បាយដូចជាមច្ឆា ហើយវិលត្រឡប់ទៅអាស្រម, ដោយត្រាច់តាមដងព្រៃ, រត់តាមផ្លូវដើរមានសភាពងងឹត ដូចនាងរុក្ខទេវតាត្រាច់លេងសប្បាយកំសាន្ត ៗ*

## ព្រះបាទទុច្ចន្តៈ

ភូមិភាគដែលអាស្រមនេះ ស្ថិតនៅគឺតាំងនៅក្រោមព្រះរាជាធិបតីភាពនៃព្រះបាទទុច្ចន្តៈ គ្មានព្រះមហាក្សត្រិយ៍អង្គឯទៀតណា នៅលើផែនដីអាចមានតេជានុភាពយកប្រៀបធៀប នឹងមហារាជអង្គនេះបាន ។ ព្រះអង្គជាស្តេចចក្រពត្រ គឺមហារាជធំជាងព្រះមហាក្សត្រិយ៍ទាំងឡាយ ។

ព្រះអង្គទ្រង់សោយរាជ្យសម្បត្តិ នៅប្រទេសខាងជើងនឹងខាងត្បូង, នៅប្រទេសខាងកើតនឹងខាងឡិច, នៅមហាសាគរទាំងទន្លេប្រាំពីរព្រមទាំងដប់បី (១) ហើយនឹងអន្តចក្រវាឡ ។

ទ្រង់មានសាមន្តរាជ នឹងពួកពលជាច្រើនជាព្រះរាជបរិវារនឹងគជេន្ទ្រនអស្សតរេន្ទ្ររបស់ទ្រង់ សុទ្ធតែសម្បូណ៌ដោយហត្ថ នឹងអស្សតរ នៅក្នុងព្រះរាជវាំងមានព្រះទីនាំងរាជវលាបល័នដោយមាសប្រាក់ ចោលរស្មីភ្លឺចាំងចែង; ព្រះបរមរាជវាំងមានព្រះរាជបរិវារប្រុសស្រីជាច្រើន ហើយមានទំហំមូលជុំវិញវែងឆ្ងាយ បើសិនណាជាមនុស្សដើរប្រហែលសក្តិរយៈវេលាពីរម៉ោងទើបបានដើរជុំ; ប្រទេសនោះល្បីល្បាញអស្ចារ្យលើភពផែនដីទាំងមូល ។

---

(១) ឲ្យអាន « ឡាពូប៉េដឺហ្វ្រូម៉ាស La poupée de Fromage » នៃទស្សនាវដ្ដីហ្វឺយ៍ឡាំង « Feuille de l'Inde » ភាគទីបី គឺជាពាក្យសុភាសិត ប្រែថាភូមិដែលមានទំហុំសម្បើមអស្ចារ្យ ។



ព្រះបាទទុដ្ឋគ្គ ៖ មានរាជមិត្តម្នាក់ដែលទ្រង់សព្វព្រះរាជហឫទ័យពន់ពេកគឺ៖ មទវ័យៈ ជាតួករបស់ព្រះអង្គ ។

មានសម័យថ្ងៃមួយ; កាលដែលគុម្ពោតរុក្ខជាតិ "មហោបិស៍" មានបុប្ផារីកស្គុះស្គាយពាសពេញ; ព្រះបាទទុដ្ឋគ្គៈ ស្ដេចចក្រពត្រ សោយរាជ្យ នៅមហាសាគរទាំងប្រាំពីរ ទន្វេដប់បី ទ្រង់មានព្រះរាជឧត្ការទៅនឹងមទវ័យៈថាៈ ។

"យើងត្រូវទៅបរបាញ់សត្វក្នុងពេលឥឡូវនេះ" ។

មទវ័យៈឮពាក្យថា; "បរបាញ់សត្វ" ក៏ញ័រខ្លួនដូចជាគេបង់គ្រុន ។

មទវ័យៈគឺមនុស្សគាត់មាំដុះពោះពេញចិត្តខាងរសនៅ ក្នុងព្រះបរមរាជវាំង ដោយបរិភោគនំអាហារផ្សេង ៗ ពីព្រឹកទាល់ល្ងាច ។ ការបរបាញ់នាំឲ្យគាត់ភ័យតក់ស្លុតជាខ្លាំង; គាត់នឹកស្រមៃទៅឃើញជុំវិញខ្លួនគាត់នូវខ្លាឃ្មុំកំណាចនឹងខ្លាដំបងសាហាវ; គាត់ស្មានថាគាត់ជាចំណីនៃសត្វសាហាវទាំងអស់នោះក្នុងព្រៃ...។ តែមទវ័យៈមិនអាចនឹងក្រាបបង្គំទូលព្រះអង្គថា ៖ ទូលបង្គំមិនព្រមទេ; សូមទ្រង់ប្រែព្រះរាជអកប្បកិរិយា យ៉ាងនេះ យ៉ាងនោះឯណាបាន ?

មទវយៈ បានស្រែកហៅព្រះរាជបរិវារទាំងប៉ុន្មានរត់មកប្រញាប់; ក្នុងមួយរំពេចព្រះទីនាំងគេជេនគេបានតែងគ្នាដាក់នាគយាន (កូប) នឹងព្រះទីនាំងអស្សរត គេយកមកទឹមព្រះរាជរថ; ពួកក្រុមរក្សាព្រះអង្គពាក់ខ្សែក្រវាត ពួកអ្នកប្រមាញ់ចាប់លំពែង, ដាងព្រួញកាន់ស្នា, ធ្នូ, ពួកអ្នកនេសាទស្ពាយសំណាញ់ ។

ក្លោងទ្វារមាសនៃព្រះបរមរាជវាំងបើកភ្លាម ហើយគេក្រឡេកទៅឃើញព្រះមហាក្សត្រិយ៍ទ្រង់គង់នៅលើព្រះទីនាំងរាជរថក្ដិចញាប; ស្ដេចយាងចាកចេញពីព្រះរាជនិវេសនដ្ឋានទៅបរបាញ់; មានព្រះរាជបរិវារដើរហែជាព្រះរាជកិត្តិយសតាមពីក្រោយព្រះអង្គ ។ នៅអមសងខាង, នៃព្រះទីនាំងគេជេនមានមនុស្សពីរនាក់លើកស្វយព្រះក្លស់យ៉ាងខ្ពស់; នៅខាងក្រៅក្បួនហែ, មទវយៈ គូកព្រះមហាក្សត្រិយ៍ជិះសេះដើងខ្ចកមួយ ។

⁜

⁜ ⁜

## ប្រមាញ់

ព្រះមហាក្សត្រិយ៍ទ្រង់ស្ដេចយាងតាមផ្លូវកាត់ទៅដល់ព្រៃធំ ដោយមានព្រៃផ្ដុំលាន់ឮអឺងកងរំពង ។ ក្នុងពេលនោះ ព្រះរាជបរិវារប្រុងប្រៀបគ្រឿងសព្វាវុធ; ព្រានបក្សាបានធ្វើអន្ទាក់ដាក់ពីគល់ឈើមួយទៅគល់ឈើមួយ; ព្រាននេសាទយកសំណាញ់ទៅបង់ត្រីតាមត្រពាំងស្ទឹង ចំណែកពួកសាមន្តរាជនឹងពលបានទៅឡោមព័ទ្ធព្រៃ ។

ព្រៃធំនោះ ទៅជាមានសភាពរដើបរង្វលដោយសត្វស្វាផ្សេងៗ នឹងសំឡេងប្លែកៗ ។

មុនព្រះមហាក្សត្រិយ៍ ស្ដេចយាងទៅដល់នៅក្នុងព្រៃនោះ សត្វទាំងអស់រស់នៅសុខសប្បាយ, ពួកបក្សាត្រដាងស្លាបហើរដោយសេរីដូចជាស្លឹកឈើ, ហើយប្រយិតប្រគោងលេងលើមែកព្រឹក្សា ប្រៀបដូចជាផ្លែឈើក្រហមដែលរយោលបក់រំកើយ ៗ ទៅលើ; កូនបក្សាទាំងនោះស្រែកយំហើរសំដៅទៅលើមេឃ, ហើយវិលត្រឡប់មកកាន់សំបុកវិញ ៗ តែក្នុងមួយរំពេច, បក្សាទាំងនោះក្រឡេកឃើញព្រាន...ហើយក៏ចាកចេញព្រឹក្សជាតិនោះ បោះបង់ចោលសំបុករួចហើរដោយភិតភ័យទៅគ្រប់ទិស ។

ក្របីខ្មៅដេកត្រាំនៅក្នុងភក់ ដើម្បីនឹងឲ្យត្រជាក់ខ្លួន, ក្រោកស្ទុះរត់ទៅក្នុងព្រៃជ្រៅ, ក្រឡេកមើលមកក្រោយងើបក្បាលដោយដឹងថាមានគ្រោះថ្នាក់ ។. មុនព្រះមហាក្សត្រិយ៍ស្ដេចយាងទៅដល់ នៅក្នុងទីនោះ ដំរីដេកត្រាំទឹក យកប្រមោយ, ស្រូបទឹកស្រោចខ្លួនវាដោយសុខស្រួល, យករូបវាទៅត្រដុសនឹងគល់រុក្ខជាតិធំ ៗ បក់មួសនឹងលាតត្រចៀកវាត្រដាងដូចស្លឹកត្នោត; ដល់ឃើញព្រានមក ដំរីនោះក៏ខ្លាច; ប្រមោយលើកឡើងលើ រត់ទៅលើអន្ទាក់បក្សាដាច់រហែកខ្ទាត់ខ្ទាយអស់,

ផាន់លើបុប្ផាបទុមក្នុងបឹង, បំផ្លាញធម្មជាតិអ៊ីៗ ឲ្យវិនាសអស់គ្មានសល់ ។

ការបរបាញ់ក៏ចាប់ផ្តើមឡើងជាបឋម ព្រៃទាំងអស់កក្រើកពាសពេញសព្ទអន្ទើហើយមានសត្វសាហាវស្រែកលាន់ឮរំពងក្នុងព្រៃ ។ ខ្លាដំបងឹបញ្ចេញសំឡេងលាន់ឮយ៉ាងខ្លាំង ក្នុងព្រៃ, ខ្លារខិនស្រែកស្ងួរសព្ទចេញពីលើភ្នំ ។

បក្សា, ជ្រូកព្រៃនឹងសត្វតិរច្ឆានស្លាប់ជាច្រើនខ្លះធ្លាក់ទៅក្នុងសំណាញ់, ខ្លះរត់ចូលទៅក្នុងអន្ទាក់ ខ្លះត្រូវប្រហារដោយដាវ ។

សូរសព្ទសម្រែកឮពាសពេញព្រៃ, ខ្លះរត់ទៅតាមផ្លូវដើរក្នុងដងព្រៃ, ក្រពើនៅក្នុងបឹងហែលលើទឹកយ៉ាងលឿន, បក្សាទាំងអស់ហើរចាកចេញសំបុក, ងងឹតមេឃដូចជាពពកមួយផ្ទាំងអណ្តែត ។

តែពួកព្រានព្យាយាមកៀរឡើងទៀត, ពួកព្រានបក្សារត់ដេញបក្សាទាំងឡាយ, ពួកព្រានកាន់ធ្នូដេញបាញ់ខ្លានឹងពួកនេសាទលើសំណាញ់ដើរលបដោយស្ងាត់ចាំបង់ត្រី ។

ឯព្រះមហាក្សត្រិយ៍ទ្រង់គង់តែមួយព្រះអង្គឯង នៅលើព្រះទីនាំងរាជរថ, ទ្រង់ដេញតាមរមាំងមួយ ។ សត្វនេះរត់លឿនដូចព្រះពាយដោយភ័យតក់ស្លុតជាខ្លាំង, ព្រះទីនាំងរាជរថលាបលនដោយមាសរត់លឿនដូចផ្លេកបន្ទោរដេញតាមរមាំងពីក្រោយ...។

បន្តិចទៀត, ព្រះមហាក្សត្រិយ៍ស្ដេចយាងទៅខាងមុខហួសពួកព្រះរាជបរិវារ, ស្ដេចសាមន្តរាជ, ព្រះរាជទេវីនាំងគេជេន, ព្រះរាជទេវីនាំងអស្សុតរ, នឹងពួកព្រះអង្គនៅពីក្រោយ, ឆ្ងាយសែនឆ្ងាយ ពីព្រះអង្គៗ

ព្រះទេវីនាំងរាជវរមាស នឹងរមាំង រត់, លោត, ផុតកន្ទុយព្រះនេត្រទៅតាមមាត់ស្ទឹង, ចូលទៅក្នុងព្រៃ, ចុងចំការ, ដល់ទៅអាស្រម...

✻

✻ ✻

## ការជួបប្រទះគ្នា

ការបរបាញ់នាំឲ្យចលាចលដល់ពួកជីវសត្វដែលនៅក្នុងព្រៃ ចំណែកខាងអាស្រមមានស្ថានភាពសប្បាយសុខស្រួល នៅមែករុក្ខាបក្សាសេកពណ៌បៃតង ចំពុះក្រហមចឹកគ្រាប់ស្រូវ ក្ងានសហែលនៅលើទឹកថ្លាភ្លឺលេងសប្បាយ ក្តាន់ដែលគេយកមកចិញ្ចឹមរត់លេងកំសាន្តនៅលើស្មៅបៃតង គ្មានខ្លាចអ្វីឡើយ ។

នាងសកុន្តលា អនសូយា, នាងប្រិយម្ពតា, តាំងបីនាក់ពួនសម្ងំលេងសប្បាយនៅក្នុងគុម្ពោតព្រៃមានស្លឹកត្រសុំសាខា ។

នៅក្នុងអាស្រមគេមិនអាចជួបប្រទះនូវសភាពភ័យអ្វីទេ ពួកស្ថាបនិកសត្វនៅទីនេះ មិនអាចមានគ្រោះថ្នាក់អ្វីសោះ ព្រោះវិន័យអាស្រមគេហាមប្រាមមិនឲ្យបរបាញ់ ។ ដោយអានុភាពនៃមហាបណ្ឌិតនាមកាមទេព ខ្លាទីងគោញីអាស្រ័យផឹកទឹកនៅជិតគ្នាហើយក្តាន់នឹងខ្លាប្រឡែងលេងរួចដេកនៅជាមួយគ្នាទៀត ។

ប្រើសដែលព្រះបាទទុស្សន្តៈទ្រង់បានដេញតាមជាប់នោះ ចូលមកលាក់ខ្លួនពួនកើតទុក្ខយំផងនៅអាស្រម; ក្នុងពេលនោះព្រះមហាក្សត្រិយ៍ទ្រង់ឈប់លែងដេញប្រើស ទ្រង់ស្តេចយាងទៅកាន់អាស្រម ព្រោះហាលនូវផ្ទ នឹងសរចេញដើម្បីកុំឲ្យទំនាស់នឹងបទបញ្ញត្តិសន្តិភាពស្ថិតនៅក្នុងទីអាស្រមនេះ ។

គឺក្នុងពេលនោះឯង, ទើបព្រះបាទទុស្សន្តៈ ស្តេចចក្រពត្រទ្រង់ប្រថាប់លើព្រះទីនាំងរាជរថមាស ងៀងព្រះនេត្រទៅឃើញនាងសកុន្តលា ដែលអង្គុយនៅក្នុងគម្ពោតផ្កា គួរឲ្យពេញព្រះរាជហឫទ័យ ។ នាងសកុន្តលា ក្រឡេកទៅឃើញព្រះមហាក្សត្រិយ៍ ... ហើយទ្រង់ទតទៅនាងសកុន្តលា ៗ ក៏ក្រឡេកមើលទៅវិញ - មកជាយ៉ាងយូរ . . . ។

## អ្នកត្លុកមធវ័យៈ

អ្នកត្លុកបានត្រាប់មកទាន់ព្រះមហាក្សត្រិយ៍ ហើយស្ថិតនៅក្នុងអាស្រមជាមួយនឹងទ្រង់ដែរ ។ តែជីវភាពបែបថ្មីនេះធ្វើឲ្យមធវ័យៈ មានចិត្តព្រួយលំបាកជាខ្លាំង តើយើងនឹងអាក់ខានលែងបានបរិភោគនូវព្រះក្រយាហារដែលដាក់លើតុព្រះមហាក្សត្រិយ៍ឬ ? តើយើងនឹងអាក់ខានលែងបាននិទ្រានៅលើគ្រែមានពូកទន់ឬ ? តើយើងលែងបានធ្វើ

ដំណើរដោយជិះលើរមាសស្រួលកាយសប្បាយចិត្តឬ ? មទវយៈ មិនមានគ្រោះថ្នាក់ជិះសេះរន្ធើននៅក្នុងព្រៃដែលគេជួបប្រទះតែនឹងខ្លា ជ្រូកព្រៃ គាត់មិនចង់អាស្រ័យទឹកល្អក់នៃបឹងដែលមានសត្វតែកក់ ៗ ដោយម្ហូបអាហារគ្មានឱជារស គាត់មើលឃើញអដជាកាសខ្មៅទាំងអស់ គាត់មិនអាចទឹងលេបនូវដុំសាច់ខ្លាបខ្មៅ ជាម្ហូបតែមួយមុខមាននៅទីនេះ ដែលគេតែងឲ្យចំពោះមនុស្សដែលហត់នឿយលំបាក ដោយធ្វើដំណើរពេញមួយថ្ងៃមកកាន់អាស្រមនេះ ; គាត់មិនអាចនិទ្រាលក់ផ្ទាល់ដីនៅលើស្លឹកឈើ, ថែមទាំងមានមូសខាំផង ៗ

អ្នកត្អូញមទវយៈ ស្ថិតនៅក្នុងស្ថានទីមានសភាពលំបាកពន់ពេក, រូបគាត់ទ្រមដោយនិទ្រាមិនបាន គាត់ញាំរន្ធត់ជានិរន្តរ៍ ក្រែងខ្លាឬជ្រូកព្រៃមកខាំបរិភោគ ហើយកាន់តែស្គមថមថយកំឡាំង ៗ

បន្តិចទៀតមទវយៈ ដែលជាមនុស្សធំធាត់ ប្រែរូបរាងទៅជាស្គមនៅតែឆ្អឹងដូចស្រមោលៗ គាត់បានពិសោធន៍មើលព្រះទ័យព្រះមហាក្សត្រិយ៍ :

ពាក្យប្រាំមួយ

“ សូមស្តេចចក្រ- ពត្រួចមកព ទ្រង់មេត្តា
ទូលទ្រង់ថា គួរចាកចេញ អាស្រមបង់
វិលសេមា ទ្រង់កុំគង់ រាជបំណាន់
ព្រះអង្គឆ្ងង់ ព្រះញាណាឆ្ងុះ មិនសមទ្រង់ ៗ

បើទ្រង់គង់ ក្នុងព្រៃគិត ខ្សោយពលភាព
ទ្រង់គួរជ្រាប សោយព្រះស្ងោយ, ស្ងាត់ជាគពង្ស
ទ្រាសសុខភាព អន់ឥន់នាយ អាពាធជង់
លិចអង្គន់ ព្រះអង្គដុង លំបាកទ្រាណា ។
ធ្លូលបង្គំ ជមជយពល ឈឺមរណា
មិនធានជា ចិត្តនឹកជាប់ រាជស្ថាន
សូមព្រះអង្គ កុំអល់អែក វិលសម្រាន្ត
និវេសន៍ស្ថាន ធានសុខស្រួល ស្រស់ព្រះទ័យ ។

តែព្រះមហាក្សត្រិយ៍ពុំទ្រង់សណ្ដាប់នូវពាក្យពោល មទវិយៈ ព្រោះតាំងពីទ្រង់ធ្មៀងព្រះនេត្រទៅឃើញនាងសកុន្ដលា នៅពួនក្នុងគុម្ពោតផ្កា, ទ្រង់ទ្រេចព្រះរាជករណីយកិច្ចហើយ ព្រះទ័យទ្រង់ទោជ មានសភាពដូចតាបសវៃឆ៍មានព្រះរាជបំណងចង់ចាកចេញពីអាស្រម ។

មានមួយថ្ងៃ សម្ដេចព្រះវររាជជននីនាថទ្រង់ចង់ធ្វើបុណ្យក្នុងសាសនាជាឧឡារិក ទ្រង់បានចាត់ឲ្យទៅក្រាបទូលព្រះរាជបុត្រ តែមិនឃើញព្រះឫទធុប្ដូនៈ ទ្រង់មិនចង់វិលត្រឡប់ទៅកាន់ព្រះរាជនិវេសនដ្ឋានវិញ ទ្រង់បានត្រាស់បង្គាប់ឲ្យពួកទាហាននឹងពួកសាមន្តរាជនឹង មទវិយៈ ឲ្យវិលត្រឡប់ទៅសូមខមាទោសសម្ដេចព្រះវររាជជននីនាថវិញ ។

## ព្រះបាទទុស្សន្តៈនិងនាងសកុន្តលា

មទវ៉្យៈត្លុកព្រះមហាក្សត្រិយ៍ស្ថិតនៅសុខសប្បាយក្នុងព្រះបរមរាជ-វាំង, ព្រះបាទទុស្សន្ត; ស្ដេចចក្រពត្រទ្រង់ត្រាច់នៅក្នុងព្រៃតែមួយព្រះអង្គ ទ្រង់ព្រួយព្រះរាជហឫទ័យពន់ពេក ៗ ទ្រង់ថ្ងូរធំហើយមានបន្ទូលតិចៗថា:

"នាងសកុន្តលា, ឱនាងសកុន្តលា !"

ធ្នឹងសរទ្រង់បោះបង់ចោលក្នុងព្រៃ ៗ ព្រះភូសាទ្រង់ពាក់ចោលនៅឯស្ទឹង ៗ ព្រះកាយទ្រង់មានសំបុរដូចមាសទៅជាមានពណ៌ប្រផេះ ៗ ទ្រង់ទៅជាមានព្រះកាយខ្មៅងងឹតដូចយប់, ព្រះអង្គមានតេជានុភាពជាស្ដេចចក្រពត្រ ទ្រង់វង្វេងតែព្រះអង្គឯងនៅក្នុងព្រៃ ៗ

x

x x

តែក្នុងពេលនោះ, នាងសកុន្តលាទៅជាយ៉ាងណា ?

នាងនិទ្រានៅទីមួយដែលមានបុប្ផាបទុមរាយពាសពេញហើយនាងសរសេរលិខិតមួយទៅថ្វាយព្រះមហាក្សត្រិយ៍: សព្ទសំដីនាងហូរចេញពីហឫទ័យនៃនាង ហើយនាងបានចារិកវាចានោះនៅលើស្លឹកឈូក ... រួចនាងថ្ងូរធំដូចព្រះមហាក្សត្រិយ៍ដែរ ...

តើតាំងពីនាងក្រឡេកឃើញអង្គព្រះមហាក្សត្រិយ៍ ចិត្តនាងយ៉ាងដូចម្ដេចទៅ ? នាងមិនដឹងទេ .... នាងដឹងថា បើព្រះមហាក្សត្រិយ៍ទ្រង់

យាន់ទៅឆ្ងាយពីនាង ៗ ចិត្តរបស់នាងលំបាកពន់ពេក .. ហើយនាងមិនអាចឃាត់ទឹកភ្នែក កុំឲ្យហូរចេញមកស្រោចស្រប់តាមថ្ពាល់នាងបានឡើយ ៗ នាងមិត្តទាំងពីរនាក់បានព្យាយាមថ្នាក់ថ្នមលួងលោមនាងកុំឲ្យនាងព្រួយបារម្ភអ្វី; នាងទាំងពីរបានយកដៃទន់ឱបនាងសកុន្តលាដឹកដៃនាង យកស៊ុកឈូកបក់ហើយយកជាយអាវជូតទឹកភ្នែកជូននាង :

ពាក្យប្រាំបួន

ព្រះអរុណា រះភ្លឺស្រាង ពេញមេឃា
ព្រះទ័យា កុំព្រួយប្រាណា នាងប្អូនគង់
យើងមុខឃើញ ទុជ្ជន្ត: បង់ចំបង
ទុក្ខព្រួយអង់ នាងកុំអួល ស្ដេចយាងមកៗ
ចូរនាងអូន កុំអស់ឃក សង្ឃឹមបាន
កែវកល្យាណ ចូរសម្រាន្ត កន្សែងយក
ជូតទឹកភ្នែក កុំភ្នកនឹក មិនបាច់រក
ចំចែរចូក ឲ្យបានជួប ព្រះរាជា ៗ
ត្រង់កាលទេត ឃើញនាងអូន ស្រស់ប្រិមប្រិយ
កាយរស្មី ភ្លឺចាំងចែង មិនរួញរា
ព្រះទ័យត្រង់ មុខជាត្រេត រកពុំផា
ជាការិយា ទុជ្ជន្ត: ស្ម័គ្រស្មោះអង្គ,ៗ

ហើយតើមានព្រឹត្តិការណ៍យ៉ាងណាទៀត ?

បន្តិចទៀតថ្ងៃក៏ភ្លឺឡើង ព្រោះយប់ដែលប្រកបទៅដោយទុក្ខផុតរលត់ក្នុងពេលនោះ; នៅលើមែកព្រឹក្សានិមួយៗ មានបុប្ផាមួយរីក; នៅក្នុងរុក្ខជាតិមានបក្សាជាច្រើនយាសយំ ... ក្ដាន់ចូលមកជិតនាងកញ្ញា ។

ហើយរូបតើអ្វីទៀត ?

រូប, នៅម្ខាងផ្លូវដើរ, ព្រះស្វាមីនាង យាងចេញពីព្រៃមកជិតគុម្ពោតឈើផ្កា ។

រូប តើអ្វីទៀត ?

រូបៈនៅក្នុងព្រៃព្រះបាទទុស្សន្តៈ, ចក្រពត្រាធិរាជនឹងនាង សកុន្តលា បានចែកកម្រងបុប្ផា (១) ទាំងពីរទៅវិញ-មក ។

ពរជ័យមង្គលអ្នកទាំងពីរក៏បានសម្រេចដូចបំណង ។

ហើយ, តើមានព្រឹត្តិការណ៍អ្វីតទៅទៀត ? ពីរបីថ្ងៃក្រោយ, ពេលបុព្វណ្ហសម័យ, ព្រះមហាក្សត្រិយ៍ទ្រង់គង់ក្នុងព្រះទីនាំងរាជរថ, ទ្រង់ចាកចេញពីអាស្រមហើយទ្រង់វិលត្រឡប់ទៅកាន់ព្រះរាជធានីវិញ ។

(១) បុប្ផា, នៅប្រទេសឥណ្ឌា, គេពាក់សម្រាប់ជាសញ្ញា ដូចជាចិញ្ចៀនអាពាហ៍ពិពាហ៍ ចងភ្ជាប់ចិត្តប្រុស ដែលជាគូសង្សារ ។

ចុះនាងសកុន្តលា ?

នាងសកុន្តលា, នាងចូលទៅកាន់អាស្រមជាមួយនឹងនាងមិត្តទាំងពីរនាក់តាមផ្លូវដើរ, ងងិត ។

ព្រះមហាក្សត្រិយ៍ទ្រង់ចូលទៅកាន់ព្រះរាជនិវេសនដ្ឋាន , ហើយនាងសកុន្តលាស្ថិតនៅក្នុងព្រៃ, រាប់ម៉ោង, ថ្ងៃ, ព្រោះមុនព្រះរាជាស្ដេចយាង, ទ្រង់បានព្រះរាជទានទៅនាងនូវទម្រង់មួយ ហើយទ្រង់មានព្រះរាជតម្រាស់ថា:

“ ឱនាងសកុន្តលាស្រី កែវប្រឹមប្រិយ ទេពធិតាឱ្ង បងសូមជូននាងទម្រង់ក្នុងបុប្ផាបង្ហួនជាសក្ខា ។ ចូរនាងទន្ទេញអក្សរនាមមួយថ្ងៃកាលយាមកនិដ្ឋ ដល់នាងចាំស្ទាត់ទុស្សន្ត ទើបនាងយាត្រាកែវពិសី ។ នាងឃើញជាក់សាយណ្ហសម័យ, រាជរថថ្នាថ្ងៃផ្លូវវិថី — អគ្គមហារាជមកទទួលខ្ញុំ ស្រស់ស្រីយកទៅរាជវាំង ” ។

ឱកម្មអកុសល ព្រះទីនាំងរាជរថនាងមិនឃើញសោះ ។

តើព្រះទីនាំងរាជរថនោះនៅទីណា ?

តើនាងសកុន្តលា បានពោលនូវព្រះបរមនាមព្រះបាទទុស្សន្ត: ព្រះមហាក្សត្រិយ៍ជាទីពេញចិត្តរបស់នាងប៉ុន្មានដងហើយ នាងមិនឃើញមហារាជាស្ដេចយាងមកសោះ ?

ឱអនិច្ចា, អនិច្ចា, ព្រះទីនាំងកែវថ្មមាសបាត់លែងឃើញស្រមោល ក្នុងសាយណ្ហសម័យ; មេឃក្រហមដូចមាស ព្រះទីនាំងនេះបាត់ លែងត្រឡប់មកវិញ ?

ឥឡូវនេះ ព្រះចក្រពត្រាធិរាជទ្រង់គង់នៅលើរាជបល្ល័ង្ក ឆ្ងាយសែនឆ្ងាយពីអាស្រម ឯព្រះរាជិនីនៃព្រឹក្សព្រៃទ្រង់គង់នៅក្រោមអាស្រម រង់ចាំព្រះស្វាមី ៗ ពីមុនព្រះមហាក្សត្រិយ៍ទឹងនាងជួបជុំគ្នា ឥឡូវឃ្លាតចាកឆ្ងាយដាច់ស្រយាល, ពីដើមអ្នកទាំងពីរស្និតនៅជាមួយគ្នា, ឥឡូវស្និតនៅឆ្ងាយ សែនឆ្ងាយ ៗ

×

× ×

## បណ្ដាសានៃឫសីទុរវាសៈ

សេចក្ដីព្រួយទុក្ខលំបាកក៏កេពានទន្ទ្រានចូលទៅក្នុងហឫទ័យនៃនាងសកុន្តលា ៗ ចិន្តារបស់នាងគ្មានអ្វី ដែលចូលមកស្ថិតនៅបាន, នាងមិនបានទទួលពួកបាហុនក៍ (ភ្ញៀវដ៏ឧត្ដម) នៃអាស្រមបទ; នាងមិនអាចលេងជាមួយនឹងក្ដាន់, នាងមិនចង់ចាំមើលមុខនាងមិត្តទីផង ·ហើយនាងមិនបានឈប់នៅមុខគុម្ពោតផ្កា; បបូរមាត់នាងមិនដែលញញឹមសោះ ហើយភ្នែកនាងជាភ្នែកខ្មៅជាំដោយអត់ងងុយ ៗ

នាងឈរនៅមុខអាស្រមបទឥតកម្រើក, ទឹងក្ដល់ដូចជារូបចំឡាក់ ហើយនាងមានចិត្តគិតទៅព្រះមហាក្សត្រតែម្យ៉ាង:

— “តើហេតុម្ដេចបានជាមហាពជជាទីពេញចិត្តរបស់ខ្ញុំម្ចាស់ស្ដេចមិនយាងត្រឡប់មកកាន់អាស្រមវិញ? មិនគួរព្រះអង្គភ្លេចខ្ញុំម្ចាស់សោះ?”

មានកាលមួយថ្ងៃ នាងកំពុងតែគិតទៅព្រះមហាក្សត្រដោយបរិទេវ ហើយយកដៃខ្ទប់មុខ; តាបសទុរវាសៈ ដែលមាននាមល្បីល្បាញជាងគេអញ្ជើញមកលេងឯអាស្រមបទ; តាបសអញ្ជើញមកជិតអាស្រម, តែនាងសកុន្តលាទុក្ខលំបាកជាខ្លាំង, មិនបានដឹង-ឮថា តាបសអញ្ជើញទៅ; នាងមិនបានចាំងើបក្បាលផង ៗ

តែទុរ្វេសៈ មានចិត្តដូចក្អែងចំបើង (មះនោះឆេវឆាវ) គ្រាន់តែមានពាក្យមិនគួរគប្បីបន្តិចបន្តួចនាំឲ្យគាត់ធ្លួលឆេះមួយរំពេច ៗ ចំពោះវាចាដែលគាត់ស្អប់អាចធ្វើមនុស្សពោលនេះឲ្យរលាយទៅជាផេះ តែនាងសកុន្តលា ក្នុងពេលនោះ ទទួលតាបសទុរ្វេសៈ ដោយសេចក្តីប្រមាទ នាងមិនបានរត់ទៅទទួលទឹងមិនបានគោរព ទាំងមិនបានអញ្ជើញលោកអង្គុយនៅទីដ៏សំគួរ ហើយមិនបានស្រោចទឹកត្រជាក់លើជើងលោក តាមប្រពៃណីបុរាណ ។

តាបសទុរ្វេសៈ ក៏ប្រឡោតខឹងជាខ្លាំង ហើយស្រែកមានសព្ទស្បូរលាន់ឮរំពងថាៈ

ឆាងប្រមាថ មើលងាយអ្នកតា ដំណើរពិត
មេឃងងឹត អញ្ជរងា ទោមនស្សអង្គ
ត្រូវធ្វើទោស មានទំងាស់ អញមិនចង់
ចោលនាងបង់ ស្តេចចាកាចាត់ លែងស្គាល់ទ្រង់

នាងសកុន្តលាកំពុងសញ្ជប់សញ្ជឹងកើតទុក្ខពន់ប្រមាណ មិនបានឃើញទុរ្វេសៈ នាងមិនបានឮវាចាគំនុំព្យាបាទរបស់តាបស នាងមិនបានដឹងថាតាបសនោះចាកចេញពីអាស្រមផង ក្រោយដែលបានពោលនូវវចីទុច្ចរិតគួរឲ្យសម្បើមអស្ចារ្យ ៗ នាងស្ថិតនៅអង្គុយស្ងៀមស្ងាត់ដោយមិនបាននឹកនាអ្វីឡើយ ។

តែនាងអនសូយា នឹងនាងប្រិយម្ពទា ជាកល្យាណមិត្តីរបស់នាង ដែលបានបេះបុប្ផានៅជិតនោះ នាងបានឮនូវពាក្យបណ្ដាសាតាបសទុវ្វាស: ... ៗ នាងទាំងពីរភ័យតក់ស្លុតជាខ្លាំង បានរត់មកកាន់តាបសនេះ, ខំព្យាយាមអង្វរតាបសកុំឲ្យទោមនស្សអ្វីឡើយ; នាងខំលុតជង្គង់សំពះតាបស ចាប់ដៃតាបស ជូតធូលីដែលជាប់បាទជើងតាបស; នាងទាំងពីរបានសូមប្រព្រឹត្តអោនលំទោនតាបសទាល់តែ តាបសអាណិតអាសូរនាងសកុន្តលា យល់ព្រមកែពាក្យបណ្ដាសា ដែលបានពោលមកពីមុនថា :

អានមួយថ្ងៃ ព្រះម្ចាស់ថ្លៃ ចក្រាពត្តិ
ទ្រង់ភិត្តន៍ យកានទ្រង់ ព្រះរាជនាង
ចំពោះនាង ស្រីធឹមធ្នួន ទ្រង់ជ្រាបញ្ញាណ
លែងរុកាភាន មុខខានឃើញ សកុន្តលា ៗ
ទ្រង់មិនយល់ កាយយូរយារ ធ្ងន់ទ្រង់
ព្រះនាមទ្រង់ វេចនាត្រង់ ត្មានតណ្ហា
លែងធឹកធា ដល់នាងនាថ កែវការិដ្ឋា
ពាក្យសច្ចា របស់តា ឲ្យនាងចាំ ៗ

ក្នុងពេលនោះ ព្រះមហាក្សត្រត្រូវមន្តតាបសទុវ្វាស: ទ្រង់គង់ជា

សុខស្រួលនៅក្នុងព្រះបរមរាជវាំង ទ្រង់ភ្លេចនូវជីវភាពរបស់ទ្រង់នៅអាស្រម ហើយដែលទ្រង់សន្យានឹងនាងយ៉ាងណា ទ្រង់ភ្លេចអស់លែងនឹកនាដល់នាងសកុន្តលា, ទ្រង់មិនបានបរព្រះរាជរថមាសទៅដល់ផ្លូវជើង, ក្នុងព្រៃដែលនាងសកុន្តលាបានរង់ចាំ ។

## តាបសកាមទេពវិលត្រឡប់មកកាន់អាស្រម

ដល់តាបសទុរវាស: ចាកចេញពីអាស្រមទៅហើយ តាបសកាមទេពវិលត្រឡប់មកដល់អាស្រមវិញ តាបសបានទៅស្វែងរកគ្រប់និគមជនបទក្នុងពិភពលោក នូវស្វាមីមួយឲ្យសមរម្យនឹងនាងសកុន្តលា គ្មាន ។

តែតាបសបានឮថាព្រះបាទទុស្សន្ត: ស្តេចចក្រពត្តិទ្រង់បានប្តូរនឹងនាងសកុន្តលា នូវកម្រងផ្កាមង្គល តាបសកាមទេពមានហសនចិត្តពន់ពេក; លោកតាបានចាត់ឲ្យហៅនាងមក, ប្រាប់នាងថាលោកនឹងនាំនាងទៅជួបនឹងព្រះមហាក្សត្រ ព្រះស្វាមីក្នុងពេលនេះ ។

នាងសកុន្តលាកើតទុក្ខចុកឆព ព្រួយប្រាណកាយពន់ប្រមាណ បានចូលមកជិតតាបស ហើយក៏ដួលនៅជិតជើងនាងពោលទៅកាន់លោកតាថា នាងបានរង់ចាំព្រះមហាក្សត្រទ្រង់មិនបាន យាងមកកាន់អាស្រមវិញ; តាបសក៏បានទំលួងលោមនាង ហើយបានឲ្យពរសព្ទ

សាធុការនាង, នាងទាំងពីរនៅពូនទីងគុម្ពោតបុប្ផា បានឮពាក្យ តាបសំកាមទេពពោលទៅកាន់នាងសកុន្តលាថា :

– “ម្នាលកូនស្រី នាងទៅជួបព្រះមហាក្សត្រព្រះស្វាមីឯបរមរាជវាំង” ។

ម្ល៉ោះហើយ នាងមានចិត្តរីករាយពន់ពេក នាងប្រិយម្វទា បាន យកកម្រងផ្កា ហើយនាងអនសូយា យកប្រេងក្រអូបហើយនាងទាំងពីរ បំរុងនឹងតុបតែងកាយឲ្យនាងសកុន្តលា ។

នាងទាំងពីរចំណាបសក់នាងសកុន្តលាឲ្យរលើបរលង់ភ្លឺចិញ្ចាច បាន គូរលើថ្ងាសនូវរូប „ទិលកៈ(១)នឹងជាតហិង្គុល; នាងបានគូរជើងនឹងល័ក្ត ក្រហម. ហើយបានបកសំបកឈើស្រស់ធ្វើជាអាវវែងយកមកតុបតែង នាង ។

តែនាងគរុណីមិនបេះពេញចិត្តនឹងការតែងតួរបស់ខ្លួន ។ តើនាង ទាំងនោះតុបតែងនាងសកុន្តលា បែបយ៉ាងណាទៀត នាងយកដើមបទុម មកធ្វើជាខ្សែដៃពាក់ឲ្យនាងសកុន្តលា; យកបុប្ផាកម្រងមកធ្វើជាខ្សែក ពាក់នាង; យកបុប្ផាម្ទេះក្រងធ្វើជាក្បាំងម្កុដ; ហើយសំបកឈើធ្វើជា គ្រឿងសំលៀកបំពាក់របស់នាង តើនេះឯងជារបៀបតែងព្រះអគ្គជា ព្រះរាជិនី ?

(១) ទិលកៈ រូបគំនូរដែលគូរលើថ្ងាសពួកនារីដែលបំរុងនឹងរៀប វិវាហមង្គលការ ។

ពួកយុវតីស្រែកថា: គួរឲ្យអនិច្ចា គួរឲ្យអនិច្ចា តើនឹងធ្វើយ៉ាងណា ហើយនាងទាំងពីរ ស្រែកច្រៀងថា៖

"ខ្ញុំត្រូវការ គងខ្យង់ខ្ជាប់ ធ្វើខ្សែក
ខ្សែមាសស សាច់ក្រហម ថ្មដោតក្រង
ត្រូវការពេជ្រ រលេចពណ៌ ផាងប៉ុនប៉ង
ខ្សែច្រវាក់ចង ភ្លឺចាំងចែង តែងនារី ៗ
តើត្រូវការ ប្រកាបការិច្ច តែងអង្គប្រាណ
ផាងចង់ចាន ឆុមុះ មាសដប់ពីរ
ចង្កាជើង លំអរជាប់ ភ្លឺគ្រប់ទី
ភ្លឺអគ្គី រាលដាលពេញ ដូចរស្មី ៗ
បើព្រះនាង ចាងសារី មកក្រងធៀត
សាច់សល្អៀត ល្អិតស្រាលស្តើង ក្បូរបតី
ដូចព្រះពាយ បក់តែនពន្ធ លើកាយស្រី
កាបស្បូរស្ដី ច្រាការស្តែង នារីឯក ៗ

ពួករុក្ខទេវតាបានស្តាប់នូវចម្រៀងនៃនាងទាំងពីរដែលបួងសួងដល់ខ្លួនក៏មកជួយឧបត្ថម្ភនាងឲ្យបានសម្រេចដូចបំណង ស្រាប់តែមានសំ-ពត់សារី (គោសេយ្យពស្ត្រ) មួយ ប៉ាក់ដោយមាសធ្លាក់ពីលើដើមឈើ

ព្រមទាំងខ្សែកគជាមួយនឹងនុប៉ុរៈ (១) មាសមានបង្រ្កង់ត្បូងសព្វ សូរពិរោះ អស្ចារ្យ ។

ក្នុងមួយរំពេច ដោយតេជៈនៃទេវតាដែលមានចិត្តសប្បុរស នាងសកុន្តលា ក្មេងនៅព្រៃ ប្រែទៅជាព្រះអគ្គមហេសីនៃស្តេចចក្រពត្តិ ។

ពេលវេលាដែលនាងនឹងចេញទៅជិតដល់ហើយ ៗ គួរឲ្យអនិច្ចា ជើងនាងសកុន្តលាមិនចង់ទៅឆ្ងាយ ហើយចិត្តនាងមិនចង់ចេញពីអាស្រមបទនោះសោះ ។ នាងមិនដឹងជាគិតធ្វើយ៉ាងណា ? តើនាងត្រូវចេញដំណើរទៅដោយក្រអឺតក្រទម ដូចជាព្រះអគ្គមហេសីចំរុងទឹង ចូលទៅក្នុងព្រះបរមរាជវាំងនៃស្តេចចក្រពត្តិ ឬត្រូវតែនាងនៅជាមួយនឹងនាងមិត្តទីពីរនាក់ក្នុងអាស្រមបទ ដែលនាងធ្លាប់រស់នៅមកហើយឬ?

ពេលដែលឃ្លាតចាកគ្នាជិតដល់ហើយ តែកិច្ចការប្រាស្រ័យគ្នាគួរសមមិនទាន់ចប់ផុតនៅឡើយ ។

ដើម្បីនឹងចាប់ទាញនាងសកុន្តលាទុកនៅតម្ពាតផ្កា ពួកកូនឈើតូច ៗ ក្រឡេកមើលនាងដោយបញ្ចេញសន្ទឹកស្រស់បំព្រង់ កូនក្តាន់កំព្រាប្រតោងសារីមាសនាងសកុន្តលា បំណងនឹងទាញនាងឲ្យវិលត្រឡប់ទៅព្រៃវិញ ។

---

(១) នុប៉ុរៈ : កងជើង ។

ឯនាងមិត្តនីទាំងពីរនាក់ គេនាំធ្វើអ្វី ក្នុងពេលនោះ ។

នាងទាំងពីរថររងិយំឱបគ្នាទៅវិញមក ។ សេចក្ដីកើតទុក្ខជាខ្លាំង នឹងចិត្តទន់ទោរទៅនាងទាំងពីរ ធ្វើឲ្យចិត្តនាងសុគន្ធលារញ្ញាកក្នុងការធ្វើដំណើរនេះ ; នាងមិនដាច់ចិត្តនឹងបញ្ចោល នាងទាំងពីរជាកល្យាណមិត្តនីរបស់នាង.... នាងមានចិត្តរេរាមិនប្រាកដ.... នាងទៅជាអស់កំឡាំងរូបស្រាប់តែនាងសម្រេចនូវរឿងការនេះ ក្នុងមួយរំពេច ។ នាងប្រគល់វត្ថុទាំងប៉ុន្មានឲ្យបិតានឹងនាងមិត្តនីទាំងពីរនាក់ ថែទាំគ្នាដោយពោលពាក្យថា ;

ពាក្យប្រាំបួន

ឱកាមទេព បិតានិព្វ ពេញចិត្តខ្ញុំ
លោកជាធំ សូមឲ្យថែ ក្នុងក្ដាងក្ដួល
ចិត្តខ្ញុំក្ដុក មិនយល់ក្ដី ជ្រៀងកំស្លួល
ខ្ញុំអាកអួល ដូចបង់ស្រី មាតាឯក ។
ខ្ញុំទៅឆ្ងាយ ទុកកុំធ្វល់ ចូរមេត្តា
ក្ដាន់នេះណា គួរអាណិត ស្ងួនអនេកា
មនោស្ម័គ្រ មានចិត្តស្មោះ ថែទាំតែគា
ទូនខ្ញុំបែក ចោះបង់ចោល ចាកអាស្រម ។

3

ប្រិយមិត្ត- នាអនា- ស្ទើយាជាន់
ល្អរូបរាង ម្អូនរួញរា ទ្រូងក្រៀមក្រោម
ឃ្លាតចាកបង ចោះបង់ចាត់ ទុក្ខព្រួយដំ
មានទារម្ភ សូមឆាន់ចាំ ជួយថែនាំ ។
រត្នាបុប្ផា ព័ណ៌សងង់ ខៀវសៀងខ្ចី
ចូរស្រស់ស្រី ព្យាយាមស្រួល ទ្រទ្រង់តាំ
ស្មៅស្លុំព្រៃ ឆាន់ប្រុងប្រៀប បង់ណែនាំ
ខ្នះខ្នែងទ្រាំ ទម្រាំម្អូន មានរាសនា ។

នាងសក្កុន្តលាផ្តាំបិតានឹងនាងទាំងពីររួចយំបោកខ្លួនថ្ងូរថា ៖

## ពាក្យប្រាំពីរ

អនិច្ចាខ្លួនចាកអាស្រម កម្មផលមកចំខានឃើញក្តាន់
ចិត្តក្តុកក្តួលអួលដាក់ស្បាន់ ព្រាត់ប្រាសព្រះបន្ទូលមេឃា ។
ព្រាត់ដីផ្កាស្មៅល្វឹងព្រឹក្សព្រៃ ស្រះណោះសត្វរែអរញ្ញា
ឃ្លាតចាកចេញឆ្ងាយពីគង្គា ធ្លាប់ងូតទិវាហែលសប្បាយ ។
ស្រះណោះឈូកស្នេហ៍កំពីងពួយ កន្ទ្រង់ទុក្ខព្រួយក្តៅក្រហាយ
ព្រលិតប្រលោមដេញទឹកខ្លាយ ផ្កាសបេញផ្សាយក្លិនគន្ធ ។

លំបង់ស្ល័ក្តដេរុក្ខជាតិ
ផុះផលសាព្រាតឈូកឡើងផង
វារីជាតិដូចស្ដេចលូកល
កុកសកូតទ្រលើសំណាត់ ៗ
ត្រីឆ្តាំងឆក់ណ្ដងហែលដិតត្រឹម
ត្រីក្រាញ់លន្ទឹមក្រុសពួយកាត់
ត្រីរស់ឆ្តោឆ្តិនដេញខ្លាយខ្លាត់
ក្រសារហើរបាត់លន្ទោបឆ្ងាយ ៗ
ត្រដក់អកអួលអាក់ចង់យំ
ចចាតហើរទំលើដើមស្វាយ
សារិកាកៀង់គូដូចឆោមឆាយ
ជួបជួនអែបកាយមហាក្សត្រ ៗ
វនាលទុង់ទទះស្វាបស្រែក
ចិត្តមិនចង់បែកកម្ពុំបាត់
សេកហើរអាកាសប្រាសទៅបាត់
មានស្ទាំងហើរកាត់កាចសាមាន្យ ៗ
យកទៅបរិភោគធ្វើអាហារ
ព្រាត់ប្រាស់សង្ខារមិនបានក្សាន្ត
សត្វដីសត្វប្បាប់គ្រប់រូបប្រាណ
មនុស្សលំអានតែង់ធម៌មនុស្ស ៗ
មកនៅស្រុកទុក្ខថាសូមសុខ
បង្កើតក្រុមកុកចិត្តក្បត់ទ្រុស្ត
មិនដែលកាចខាំសុនខព្រុស
មនុស្សមួយចាក់ផ្ទុះពាផែនដី ៗ

## កាកគតិ

ជៅពេលយប់យន់ សត្វយំគ្រួកវន្ត ពាសពេញ ស្ទឹកាទ្វី មានកុម្ភោតផ្កា រុក្ខាថែខ្វី សព្វស្សរជត្រី ពោលស្តីពីរោះ ៗ ពពកាសសាត់ សត្រាហាមខ្លាត ផាត់ផាយវាយឃ្មោះ ស្វត្រូងម៉បង្កី ពុស្ចរធីកាជ្រោះ

ហ្វូមកាក្ងានឈ្មោះ ដូចស្រីច្រៀងកំ ៗ ព្រះចន្ទ្រចាំងចែង
រស្មីភ្លឺចែង តារាត្រាច់នាំ អាចន្លាយផ្កាកព្រុះ
មានទៀតកាឈរឃ្មាំ ពីទុយមៀមពាំ ផ្លែស្វាយ[illegible]គោគ ៗ
រសឹកាយប់ស្ងាត់ ភយោផាយផាត់ ប្រកាបជ័យនោគ
រសឹកាឌុឌ្យាន ត្រូឡាចត្វឹមហ្វាក ខុជ្ជាក្ងិនយោគ
ក្រាអូបឈូយឈួប ៗ មានពណ៌ទៀរលៀង សម្បូរ
សម្រឿង បៃតងទ្រាវគូ ក្រាហមប្រាលខ្មៅ ស្ពាន
ស្នូតគ្រែបជប់ សម្បាយសព្រុំ ព្រលប់និទ្រា ៗ
តែក្ងស្រាកាកូកាយ គួរឲ្យក្ដៅធំ ភយោរដ៏ា ទអាំង
ក្លាក់ក្រឹង ខ្វាអញ្ញាភ លាងពុមេឃា សម្រែកាដំរី ៗ
សត្វស្លាប់សំពោច ស្វាពង្រួលនោច យំលើដើមស្ដី
កាណ្ដូរត់ពេញ តុកកែពោលស្ដី ជីងចក់អម្រើ
ជំងូសស្ទុចរុយ ៗ

## ព្រហ្មគីត

ដើមស្ដៅចិត្តប្អូនស្ដាយ ទឹកដើមស្វាយសន្តែកគុយ
បង់ទុំរំលោកកុយ មានទុក្ខយំដើមគរ ៗ
ដើមដូង់ដូបប្អូនដង់ ទ្រូងគានតឹងស្រយំឈរ

ឃើញព្រះភក្ត្រស្ដាយផរ ទ្រង់ប្រទានពរជ័យគ្រប់យ៉ាង ៗ
សុក្រមប្អូនកម្ស្រាស យាង់ក្រឡាស់ចិត្តឡើងបាន
ក្រឡាញ់ក្រឡឹងខាង មុខក្រឡន់ក្រឡេកផ្សង ៗ
ផ្ទឹកផ្ទង់ចិត្តស្នេហា ឃើញកន្ត្រាផ្កាតបារបង
ស្វាមីចិត្តក្ដាប់ផង ព្រួសារសង់ស្បូរល្វឹងល្វើយ ៗ
ដើមត្រើងទំប្រឹងនឹក ថ្ងៃយប់ព្រឹកស្ដេចសៀមជឿយ
ឲ្យប្អូនគិតរឿយ ៗ ទំរិះរកមិនយល់កល់ ៗ
ដើមកៃសុស្ដេចគេចកៃ ព្រះទ័យប្រែឲ្យនាងផ្ទួល់
ដើមគគិតមិនដល់ ចលាចលនគរកាយ ៗ
គួលេនកន្ត្រញញឹម ក្រួចក្រាញលឹមព្រលប់ឆ្ងាយ
ស្ដេចក្រៃគង់ជួបនោមឆាយ មានប្រឡាយទើបទឹកហូរ ៗ
ព្រហូតប្រហាតមាត់ ត្រៃបែកព័ន្ធត្រប្បាញ់ស្បូរ
ត្របកឈូកមិនជួរ ដូចស្រីប្ដូរផ្កាប់ក្អែកបូល ៗ
ដើមលោតលង់តណ្ហា លិចផលសាព្រប្រផ្ទួល
យល់ផ្ចត់ពោះបេញចូល ដើមចៃង៍ហូលផ្គាប់ក្ទិនថ្មី ៗ
ដើមបារបង់ចិញ្ចៀន នឹកដើមមៀនព្រះជិនស្រី
ក្ដឹស្វាង៍រំលប៉ី ក្ដេចបេតីឲ្យនាងសោក ៗ

ដើមកំរងចិត្តរងរូស ដើមចេកគូសចង់ស្តេចពោក

វែងគិតមិនចង់ក្រោក ដើមកំពោកបពាមុខ ៗ

## ពាក្យ ៩

ក្តុលាបគំ ចិត្តរបក្ខូន កាលកាបកិច្ចុ

នឹកមិនភ្លេច ព្រះស្វាមី ក្តីស្នេហា

ផ្កាចេកធំ ធតគ្រប់ទិស ស្អាងអាត្មា

រូបកាយា ប្រកាបយស ឃ្លាតយូរយារ ៗ

ផ្កាចេកទេស ធ្វើចិត្តនាស់ ប្អូនទន្ទឹង

ចំប៉ីប្រឹង ប្អូនចំពើប ចំពោះមារ

ចំប៉ាប៉ង ជ្រកម្លប់ពោធិ កែវពូជធារ

ធ្វើការងារ ប្អូជាខ្ញុន សាសនាជាតិ ៗ

រំចេកចុង រំដួលចិត្ត ចាកអាស្រម

ទ្រូងគ្រៀមក្រោម លំចាកក្រោល កម្មឃ្លាឃ្លាត

ម្ទេះលាលាក់ ប្អូនលិបលង់ ចាបលោកធាតុ

នាងនឹមនាថ តែងគិតនឹក អន្តមហាក្សត្រ ៗ

ក្តុលាបស ក្តុលាហាល ហែលសង្សារ

ទ្រូងខ្ទោចផ្សារ ចិត្តប្អូនផ្សង ផ្សាយកាំចាត់

ចាបខ្មៅសង់ ដែលចានសាង កំចាយចាត់
ឲ្យរសាត់ ទុក្ខារសាយ ដល់ភំនជ័យ ។
ផ្កាចន្ទ ឃើញម្កុដធំ និមិត្តយល់
កាបទសពល ឱសុខពល ដូចព្លូរជ្រៃ
ផ្កាច្បារច្បាស់ ចិត្តប្អូនច្បាំង ដុតពីភ័យ
កែព្រះន័យ លើកកាន់ទព ចូលតស៊ូ ។

នៅក្រោមព្រះពោធិព្រឹក្ស ចំពីមុខអាស្រម នាងក្រមុំទាំងពីរនាក់យំជាខ្លាំង ហើយចាកចេញពីសកុន្តលា ពោលថា:

ពាក្យ ៩

ចៅជាយជោគ សំពត់សា- រីជាន់ជាប
ឃើងចងព្រាត ទម្រង់ព្រោង ក្តីអស្ចារ្យ
ចូរនឹមខ្លួន នាងយកទៅ និស្ស័យចារ
ថ្វាយក្សត្រា ឲ្យយល់ត្រើយ ចូរនាងត្រាច់ ។
ក្នុងភំនជ័យ ប្រកបជោគ ស្តេចចក្រពត្តិ
គង់ទៀងទាត់ ចាំនាងអូន ចាបលះកាប់
បុណ្យឲ្យផល ភ័ព្វសំណាង ចានជួបស្តេច
រូបមូលសាច់ ចំក្នុសាង ថែចិញ្ចៀន ។

កុំឲ្យធាត់ មើលថែនាំ កុំធ្វេសបង់
ឧម្រង់អង្គ ព្រះចមពង្ស ចូរឈានរៀន
គម្ពីរសាស្ត្រ លោកធម្មា មន្តរបៀន
ចូលសង្វៀន បង់សង្វេគ ឃ្លាតពីប្អូន ។

រូបនាងសកុន្តលាឱនក្បាលថ្វាយបង្គំគ្រូទេវតា ទាំងប៉ុន្មាន ដែលនៅក្នុងព្រៃ វន្ទាព្រះបិតាកាមទេព ហើយត្រាច់ទៅកាន់ព្រះបរមរាជវាំង តែម្នាក់ឯង ។

នាងបានលះបង់នូវគ្រួសារទាំងអស់ ដើម្បីទៅកាន់វង្សត្រកូលដទៃ ចាកចេញពីកាស្រមបទ ដើម្បីនឹងធ្វើដំណើរទៅកាន់ប្រទេសដែលនាងមិនបានស្គាល់ ។ នាងសកុន្តលាទៅឆ្ងាយ ហើយដំណើរនាងឲ្យព្រៃទាំងអស់ស្ងួលខ្លាំង ។

✕
✕ ✕

## ព្រះឧម្រង់ទាត់

តែក្នុងពេលដែលនាងសកុន្តលា ធ្វើដំណើរទៅកាន់ព្រះបរមរាជវាំង បណ្ដាសាតែតាបសទុរវាសៈតាមជាប់ទៅជាមួយនឹងនាងផង ហើយចូលទៅស្ថិតនៅនឹងផោកក្រាសនារបស់នាង ។ កាលនាងទេះដល់មាត់ស្ទឹងសចិតិរ្ថ (Sachitirtha) នាងសកុន្តលាមិនអាចនឹងទប់ទល់ចិត្តអាក់ខាន

ផ្លូតទឹកស្ទឹងនោះបាន ៗ នាងក៏ចុះផ្លូតទឹកហែលលេងកំសាន្តសប្បាយ.. សំពត់សារ៉ែប៉ាង់ខាងលើទឹក ហើយមានសភាពស្រាលក្លីដូចទឹកសើមជាប់ សាច់តាមរលកទឹកដែលប៉ះមកនឹងសាច់នោះ ៗ

ក្នុងពេលនោះ បណ្ដាសាតាបស់ទុរ៉េសៈក៏ឲ្យផល ធ្វើឲ្យព្រះទម្រង់ ដែលមានត្រាព្រះសង្ហាររបេះពីសំពត់ពណ៌ជ្រុះទៅក្នុងទឹក ដោយនាង សកុន្តលា ឥតមានដឹងអ្វីសោះឡើយ ៗ

ដល់នាងឡើងមកលើមាត់ស្ទឹង នាងមានសក់វែងខ្មៅស្រិលធ្លាក់ លើដៃមាសនាង ហើយនាងមានកន្ត្រកស្រស់ស្រាយត្រជាក់ស្រួល នាងយកសំពត់សារ៉ែមកពាក់ហើយធ្វើដំណើរតទៅទៀត នាងបានត្រាច់ដំរង់ទៅឯព្រះបរមរាជវាំង នឹកដល់ស្ដេចចក្រពត្តិ តែភ្លេចនឹកនាពី ព្រះទម្រង់និងការទូន្មានរបស់មិត្តនី ទាំងពីរនាក់ថាៈ

នាងជាទីពេញចិត្ត ដល់នាងទៅឆ្ងាយ

នាងជាទីពេញចិត្ត ចូរនាងថែទាំព្រះទម្រង់កុំឲ្យបាត់ ៗ

## ព្រះបរមរាជវាំងនៃព្រះបាទទុស្មន្តៈ

ព្រះបាទទុស្មន្តៈ ដោយត្រូវបណ្ដាសាតាបសទុរាសៈ ទ្រង់ឥតមាននឹកនាដល់នាងសកុន្តលាសោះឡើយ ហើយទ្រង់គង់នៅជាសុខសប្បាយក្នុងព្រះបរមរាជវាំង ។

ព្រះបរមរាជវាំងនេះបែកចេញជាប្រាំពីរកន្លែង មានទំហំជុំវិញ ៧ យោជន៍ ។ នៅកន្លែងទីមួយមានប្រាសាទកំពូលមាសសរសរមាស ហៅថាសាលាតុលាការ ។ គឺនៅទីនោះដែលព្រះចក្រពត្តិទ្រង់គង់លើរាជបល្ល័ង្កមាស ទ្រង់ត្រាស់បង្គាប់ឲ្យដោះលែងអ្នកសុចរិតហើយដាក់ទណ្ឌកម្មអ្នកទុច្ចរិត ។

នៅកន្លែងមួយ ព្រះបរមរាជវាំង មានសាងព្រះវិហារ ។ ជញ្ជាំងមាសមានលំអរដោយក្បាច់ចេនាដ៏វិចិត្រ, មានក្បាច់បក្សាធ្វើពីពេជ្រ ក្បាច់ផ្លែឈើធ្វើពីគជខ្ចង់, ក្បាច់ស្លឹកឈើធ្វើពីត្បូងកណ្ដៀងខៀវ ។ នៅពាក់កណ្ដាលព្រះវិហារ មានអុបភ្លើងចេះសន្ទោសន្ទៅពេលទិវារាត្រី ដែលគេយកធូបទៀន និងគ្រឿងសក្ការទៅបូជា ។

លំដាប់មកមានប្រាសាទមួយ ដែលមានពួកបាហុនក (ភ្ញៀវ) ច្រើនមកអាស្រ័យ ហើយដែលគេយកម្ហូបអាហារមកដាក់ និងចានមាសពីរដង ក្នុងមួយថ្ងៃជូនបរិភោគ ។

ឆ្ងាយបន្តិចទៀតមានប្រាសាទ "នាដាគារ" ។ នៅលើកម្រាលឥដ្ឋរលើប គេឮស្គរទុំបុរៈស្រើរ ប៉ាំមានបង្រ្កង់ដើងពំតាមបង្អាក់ភ្លេង; តាមជញ្ជាំងថ្មកែវ គេបានឃើញនាងនាដកាជាច្រើន; រូបនាងកម្រើកបន្តិចម្តងទៅតាមបទភ្លេង ធ្វើឲ្យអ្នកទស្សនាឈ្ងក់ចិត្ត ។

ឆ្ងាយបន្តិចទៅទៀតមានប្រាសាទ "វេទ្យាគារ" ដែលមានចម្រៀងពីរោះអស្ចារ្យ ផ្សាយចេញពីទីនោះ ។ ព្រះចក្រពត្តិទ្រង់គង់នៅប្រាសាទនេះ, ផ្ទំនៅលើព្រះទែនមាស ; តាមទ្វារខាងត្បូង មានព្រះពាយបក់រំភើយ ៗ តែព្រះពាយនោះ ឥតបាននាំយកនូវរឿងរ៉ាវផ្សេងៗ ពីព្រៃមកជាមួយផងទេ ។ ខុសគួរឲ្យអនិច្ចា ព្រះចក្រពត្តិទ្រង់ផ្ទំនៅលើព្រះទែនមាស ក្នុងប្រាសាទដែលមានរបាំកំសាន្តព្រះទ័យ ត្រូវបណ្តាសាតាបសទុរវាសៈ ទ្រង់លែងនឹកនាដល់នាងសកុន្តលាសោះឡើយ ។

⚜

⚜ ⚜

ចុះនាង សកុន្តលា ?

នាងត្រាច់ក្រោមទឹកភ្លៀង និងព្យុះខ្យល់លំបាកវេទនា ទើបមកដល់ក្នុងព្រះបរមរាជវាំង ។ តែព្រះមហាក្សត្រទ្រង់មិនបានទទួលស្គាល់នាងសោះឡើយ ។ ទ្រង់មានព្រះបន្ទូលមកកាន់នាងថា: "នាងកញ្ញា តើនាងឯងមករកអ្វីក្នុងទីនេះ? តើនាងត្រូវការប្រាក់ ឬត្រូវការគេហដ្ឋាន ឬត្រូវការអ្វី?" ។

នាងសកុន្តលា ក្រាបទូលព្រះចក្រពត្តិវិញថា: "ឱព្រះអង្គ ខ្ញុំម្ចាស់គ្មានចិត្តប្រាថ្នាចង់បានប្រាក់ ឬគេហដ្ឋានអ្វី; គឺខ្ញុំម្ចាស់ចង់បានតែព្រះអង្គប៉ុណ្ណោះ; ព្រះអង្គជាស្វាមី របស់ខ្ញុំម្ចាស់ ព្រះអង្គទ្រង់បានព្រះរាជទាននូវកម្រងផ្កាសមរស ដាក់ជុំវិញកខ្ញុំម្ចាស់; គឺមានតែព្រះអង្គនេះឯងដែលខ្ញុំម្ចាស់ចង់បាន ?"

ព្រះចក្រពត្តិទ្រង់តបទៅវិញថា: "គួរខ្មាសអៀនណាស់ នាង តើនាងពោលយ៉ាងណា ? នាងជាស្ត្រីនៅក្នុងព្រៃ ហើយយើងជាព្រះចក្រពត្តិ ហេតុម្ដេចក៏យើងបានប្រគល់នូវកម្រងផ្កាមកនាង ? បើនាងចង់បានប្រាក់, យើងនឹងប្រគល់ឲ្យនាង ; បើនាងចង់បានគេហដ្ឋាន យើងនឹងឲ្យនាង; បើនាងចង់បានគ្រឿងមាសប្រាក់, នាងឯងមុខជានឹងបានមិនខាន ។ តែនាងឯងចង់ធ្វើជាព្រះអគ្គមហេសីយើង, មិនសមសោះ ?" ។

## នាង សកុន្តលា ថ្លែងរឿងរ៉ាវក្រាបទូលព្រះបាទ ទុស្សន្ត

នាងសកុន្តលា ដល់បានស្ដាប់ព្រះបន្ទូលព្រះបាទ ចក្រពត្តិ មានចិត្តរន្ធត់ញ័រអស់អង្គ : ហើយនាងក្រាបទូលព្រះអង្គថា:

"ឱព្រះអង្គ មិនគួរសោះ ? ខ្ញុំម្ចាស់នេះហើយ នាងសកុន្តលា ។ តើព្រះអង្គភ្លេចខ្ញុំម្ចាស់ហើយ ?

សូមព្រះអង្គទ្រង់ព្រះតម្រិះ, មានកាលមួយថ្ងៃ, មានស្ត្រីបីនាក់បាន ដៃដកគ្នានៅក្រោមគុម្ពោតផ្កា... ហើយព្រះអង្គទ្រង់យាងទៅដល់ទីនោះ! នាងទាំងពីរនាក់បានយកទឹកមកស្រោចព្រះបាទព្រះអង្គ ៗ ខ្ញុំម្ចាស់បានដក ផ្លែឈើទុំជាយសម្មួយ ខ្ញុំម្ចាស់យកមកថ្វាយព្រះអង្គ; ព្រះអង្គទ្រង់សោយ នូវផ្លែឈើនោះហើយទ្រង់ញញឹមផង ៗ រួចខ្ញុំម្ចាស់បានយកស្លឹកត្របកផ្កា ឈូក ដើម្បីនឹងថ្វាយព្រះអង្គធ្វើជាកន្ទោងដាក់ទឹកឲ្យកូនក្ដាន់ផឹក; តែកូន ក្ដាន់នោះវារត់ចាកចេញពីព្រះអង្គ; ព្រះអង្គទ្រង់បានហៅកូនក្ដាន់នោះមក វិញ; ព្រះអង្គទ្រង់ព្យាយាមឲ្យកូនក្ដាន់នោះត្រឡប់មកវិញដោយមាន ព្រះបន្ទូលស្រទន់ផ្អែមពីរោះ, តែកូនក្ដាន់នោះមិនព្រមមកជិតព្រះអង្គ ៗ តែកាលណាខ្ញុំម្ចាស់ហៅកូនក្ដាន់នោះ វាមកជិតខ្ញុំម្ចាស់ហើយវាផឹកទឹកនឹង បាតដៃខ្ញុំម្ចាស់ ៗ

ហើយព្រះអង្គទ្រង់មានបន្ទូលថា: “ អ្នកទាំងពីរ (នាង សកុន្តលា នឹងកូនក្ដាន់ញី, ជាស្ត្រីនៅក្នុងព្រៃ ព្រោះហេតុដូចនេះ បានជាមានមេត្រី ទៅវិញ-មកបាន ” ៗ

នាងទាំងពីរនាក់ជាមិត្តនីរបស់ខ្ញុំម្ចាស់ឮទ្រង់មានបន្ទូលដូចនោះ នាង ក៏ញញឹមចំណែកខ្ញុំម្ចាស់ទៅជាមានចិត្តអៀនខ្មាសជាខ្លាំង...

រួចតមក, ឱព្រះអង្គ, ទ្រង់បានគង់នៅក្នុងអាស្រមបទយូរថ្ងៃ ដូចជា តាបសព្រះអង្គទ្រង់សោយនូវផ្លែឈើព្រមទាំងបោយព្រះគង្គានៅក្នុងស្ទឹង ៗ

រួច...នៅពេលយប់ព្រះចន្ទពេញបូណ៌មី ទ្រង់យាងមកដល់គុម្ពោតផ្កា... ដែលខ្ញុំម្ចាស់នៅ; នៅលើមាត់ស្ទឹងម៉ាលិនី ព្រះអង្គនិងខ្ញុំម្ចាស់បានប្ដូរកម្រងផ្កាគ្នាហើយ...

តើព្រះអង្គទ្រង់ភ្លេចរឿងរ៉ាវទាំងអស់ហើយឬ ?

ថ្ងៃដែលព្រះអង្គទ្រង់យាងចេញពីអាស្រមបទ ទ្រង់បានព្រះរាជទាននូវព្រះទម្រង់មួយហើយមានព្រះបន្ទូលថា:

“ឲ្យនាងមើលអក្សរដែលចារឹកនៅលើព្រះទម្រង់ ក្នុងមួយថ្ងៃអក្សរមួយ ៗ ដល់ណានាងបានពោលនាមយើង “ទុស្សន្តៈ គ្រប់អក្សរ នាងនឹងឃើញក្នុងសាយណ្ហសម័យ នូវព្រះរាជរថបរមកកាន់ទីនេះ គឺព្រះស្វាមីនាងយាងមកដើម្បីនឹងយកនាងទៅ” ។

តែព្រះអង្គ; ឯណាព្រះរាជរថរបស់ព្រះអង្គ; ម្ដេចក៏ព្រះអង្គទ្រង់បំបាត់បោលនូវកិច្ចសន្យានោះ ។

នាង សកុន្តលា ស្ត្រីនៅក្នុងព្រៃបានថ្ងូញថ្ងូរ ក្រាបទូលព្រះចក្រពត្តិ; នាងប្រាថ្នាបញ្ជាក់ឲ្យព្រះអង្គជ្រាបនូវរឿងរ៉ាវសព្វគ្រប់; នាងបានក្រាបទូលព្រះអង្គអំពីមិត្តនីនាងពីរនាក់ កូនក្តាន់ញី គុម្ពោតផ្កា ហើយនឹងវត្ថុឯទៀតជាច្រើន... ។

តែព្រះចក្រពត្តិទ្រង់ភ្លេចលែងនឹកនាអ្វីសោះឡើយ !

លំដាប់តមក ព្រះមហាក្សត្រមានព្រះបន្ទូលសួរទៅនាងសកុន្តលាថាៈ "ឲ្យនាងបង្ហាញនូវព្រះទម្រង់នោះមកយើង នាងថាៈយើងបានឲ្យព្រះទម្រង់នោះ យើងចង់ឃើញព្រះទម្រង់" ។

នាងសកុន្តលា ក៏ប្រញាប់ប្រញាល់លើកដាយសំពត់សារីនាងដែលមានកំណាត់សំពត់ចងព្រះទម្រង់ជាប់ ព្រះទម្រង់មិនឃើញ ជ្រុះបាត់ ។

ព្រះទម្រង់ដែលមានតម្លៃស្មើនឹងឃ្លាំងប្រាក់មហាពង់ទាំងប្រាំពីរ នៅឯណា ? បណ្ដាសាតាបស ទុរវាសៈ បញ្ចេញអនុភាពឲ្យផលហើយ ។ ព្រះមហាក្សត្រទ្រង់លែងស្គាល់នាងសកុន្តលា ។

នាងសកុន្តលា ស្រែកឡើងថា "ឱមាតា គោតមី ហើយនាងក៏ដួលសន្លប់ទៅលើផែនដី នៅកម្រាលត្រដាក់ ឈាមហូរចេញពីថ្ងាសនាងដែលរបួស ហើយពួកមហាតលិក តក់ស្លុតភ័យថ្ងរធំ" ។

## គិរីកំពូលមាស

ក្នុងពេលនោះ នៅព្រះបរមរាជវាំងនៃព្រះឥន្ទ្រាធិរាជ ជាស្ដេចទេវតាទាំងឡាយ មាតាដើមនាងសកុន្តលា ៈមេនកាមានចិត្តថ្ម Maneka au cœur de pierre. "នាងកំពុងដេញពិណា ។ ស្រាប់តែខ្សែពិណានោះដាច់អស់ នាងមេនកាភាំងស្មារតីលែងគិតឃើញនូវបទចំនុកចម្រៀង ហើយនាង

បានផ្តាំទូន្មាននាងសកុន្តលា ហើយនាងអាណិតអាសូរដល់បុត្រីជាខ្លាំង ៗ

នាងក៏ហោះចុះពីស្ថានសួគ៌មួយរំពេច គង់លើទិព្វយានពពក នាងបានមកចាប់ទីដៃនាង យកនាងសកុន្តលានោះទៅដាក់លើភ្នំកំពូលមាស ៗ

នៅលើភ្នំនោះ មានអាស្រមបទនៃតាបសមួយផ្សេងទៀតនាមកស្សប ៗ

នៅទីនោះ មាននាងទេវធីតាចោមរោមជាច្រើន ហើយនាងសកុ-ន្តលាប្រសូតព្រះរាជបុត្រមួយអង្គ ៗ

សេចក្តីទុក្ខរបស់នាងមិនសូវមានអនុភាពឡើយ ព្រះរាជបុត្រនោះបំពេញចិត្តនាងឲ្យកក់ក្តៅបន្តិច ដោយនាងនៅឆ្ងាយពីព្រះមហាក្សត្រ ៗ

ព្រះទម្រង់រកាឃើញវិញ

មានកាលមួយថ្ងៃ ពួកនេសាទទាំងដើងបានយកសំណាញ់មកបង់ត្រីនៅស្ទឹងសចិតិថ៌ (Sachitirtha) បានត្រីជាច្រើន; បានត្រីខ្លះសម្បុរមាស ខ្លះសម្បុរប្រាក់ ខ្លះរាងមូលដូចព្រះចន្ទ ខ្លះទៀតទ្រង់ទ្រាយដូចពស់; ត្រីទាំងអស់នោះគរនៅលើមាត់ស្ទឹង ទទួលរស្មីព្រះសុរិយា ភ្លឺចាំងចែងរលើគោកឡូកទៅឃើញដូចជាគំនរប្រាក់មាស ៗ

ពួកនេសាទ តាំងពីព្រឹកដល់ល្ងាចត្រេកអររាប់កម្រៃដែលបានមក កក្រញញឹម ៗ

រួចទើបយប់មកដល់, ងងឹតគ្រប់ទិសៈ មេឃខៀវ, ទឹកស្ទឹងហើយនឹងផ្លូវវែងតាមមាត់ស្ទឹង ។ ពួកនេសាទយកសំណាញ់ស្ពាយវិលត្រឡប់ទៅផ្ទះវិញ ។

ក្នុងពេលនោះ មានអ្នកនេសាទមួយថ្មីមកដល់មាត់ស្ទឹងនោះទៀត; អ្នកនេះយកសំណាញ់ធំខ្មៅដូចពពកលើទវាល័យ បង់កន្លែងនេះម្តង កន្លែងនោះម្តងទៅក្នុងស្ទឹង ។

ត្រីដែលចាស់ជាងគេស្តេចត្រី ហែលចូលទៅជាប់ក្នុងសំណាញ់នោះ ។

ដំណឹងក៏ឮសព្ទសូរពាសពេញចំពោះអ្នកនេសាទៈ

មានត្រីចាស់ជាងគេមួយជាមេ ដែលធ្លាប់តែឆ្លាតប៉ិនប្រសប់មិនឲ្យជាប់សំណាញ់ ឥឡូវគេបង់បាន ?

អ្នកខ្លះរត់មកកាន់មាត់ស្ទឹង; គេបានទាញសំណាញ់នោះមកលើគោក; គ្មានអ្នកណាបានឃើញត្រីធំដូចនេះ ។ ហើយក៏វិលត្រឡប់ទៅកាន់គេហដ្ឋានវិញ ។

គេក៏បានយកមកសម្លាប់ កាត់ជាកង់ ៗ តែគេបានឃើញអ្វីដូចអណ្តាតភ្លើងនៅក្នុងពោះត្រីនេះ ? . . . ព្រះទម្រង់មានជាពេជ្រ . . . ។

អ្នកទាំងអស់គ្នាមានចិត្តឆ្ងល់ពន់ពេក ។ ចំណែកឯអ្នកនេសាទ

នោះសប្បាយចិត្តណាស់ដូចជាគេចាប់ព្រះចន្ទបាន! អ្នកនោះបោះស់-ណាញ់រហែកជាច្រើនអន្លើទៅក្នុងស្ទឹង ហើយរត់ទៅផ្ទះជាងទង ដើម្បីនឹងលក់ព្រះទម្រង់នេះ ។

ឯព្រះទម្រង់នេះ គឺព្រះចក្រពត្តិទ្រង់បានព្រះរាជទានពីអតីតកាលទៅនាងសកុន្តលា ហើយនាងបានយកទៅធ្វើបាត់នៅពេលនាងចុះទៅផ្ងូតទឹកក្នុងស្ទឹងសចិតថ ។ ត្រីបាសនេះ វាបានលេបចូលទៅក្នុងពោះស្មានថាជាចំណីថ្មែកដែលមិនធ្លាប់ស្គាល់ ។

ជាងទង, ដល់ឃើញព្រះសង្ហារមានចិត្តសង្ស័យរត់ទៅប្តឹងនាយក្រុមព្រះនគរបាល; នាយក្រុមនេះក៏នាំអ្នកនេសាទចូលទៅ ឯព្រះបរមរាជវាំង, ចំពោះនាមុខសត្វមុខមន្ត្រី អ្នកនេសាទញ័រដៃជើង ថ្លែងថាបានរកឃើញព្រះទម្រង់ក្នុងពោះត្រីបាស ។

រដ្ឋមន្ត្រីនៃព្រះចក្រពត្តិ មានចិត្តសង្ស័យបានចុនប្រមុះហិតក្លិនលើព្រះទម្រង់ ។ រដ្ឋមន្ត្រីនោះពោលថាមានធំក្លិនត្រីពិត ។

គេបានដោះលែងអ្នកនេសាទ- ហើយគេបានឲ្យរង្វាន់នូវមហូរ (mohour) (១) មួយបារ ។

---

(១) មយមហូរ តម្លៃមួយល្មីមាស ជា ២៤ លិព្រ ។

## ព្រះចក្រពត្តិទ្រង់ព្រះតម្រិះជ្រាបៈ

ដល់ព្រះចក្រពត្តិ ទ្រង់បានទតឃើញនូវព្រះទម្រង់របស់ព្រះអង្គ ព្រះស្មារតីនឹកឃើញភ្លាម; ព្រះអង្គជ្រាបច្បាស់នូវអាស្រមបទ ហើយ ទ្រង់ទៅដូចជាវិលប្រកេសព្រួយព្រះរាជហឫទ័យពន់ពេក ដោយទ្រង់ នឹកទៅនាងសកុន្តលាហើយគិតថាមិនគួរនឹងធ្វើព្រះទ័យ រឹងរូសលះបង់ ចោលនាងសោះ ។

ដូចជាភ្លើងឆេះបំបើងបន្តិចម្តងៗ សេចក្តីទុក្ខនោះឆេះដល់ព្រះឧរា ព្រះអង្គ ។ ទ្រង់មិនជ្រាបថានឹងធ្វើយ៉ាងណាហើយទ្រង់ថ្ងូររំនិវន្ត៍ៈ

“ សកុន្តល ? ឱនាងសកុន្តលា! ”

ព្រះអង្គលែងសោយព្រះស្ងោយ; លែងយាងទៅណាមកណា, លែងផ្ទំ, លែងយល់សប្តិ; ទ្រង់គ្មានសប្បាយអ្វីឡើយ, តាំងនៅក្នុង ព្រះបរមរាជវាំង, ឬនៅក្នុងឧទ្យានកំសាន្ត ។

នៅក្នុងប្រាសាទភ្លេងតូរ្យដន្ត្រី ទំនុកចម្រៀងស្ងាត់លែងឮសព្ទសូរ អ្វីឡើយ ហើយនៅក្នុងឧទ្យានកំសាន្តគ្មានពិធីបុណ្យអ្វីសោះឡើយ ។

ព្រះមហាក្សត្រទ្រង់ព្រួយព្រះរាជហឫទ័យជាអនេកប្បការ ។

ម្នាងនៅលើគ្រែកំពូលមាស នាងសកុន្តលានារីព្រៃបីទ្រព្រះរាជបុត្រា មួយអង្គ ម្នាងទៀតព្រះបាទទុឞ្យន្តៈ ទ្រង់ដួលសន្លប់ផ្កាត់បង់ព្រះស្មារតី នៅលើផែនដី ព្រួយក្នុងព្រះរាជហឫទ័យជាខ្លាំង?...

## ព្រះអង្គម្ចាស់នៅក្នុងព្រៃ

ពួកទេវបុត្រ ទេវតាទ្រង់អាណិតអាសូរព្រះបាទទុស្សន្តៈពន់ពេក បាន ចាត់ឲ្យយកព្រះទិព្វយានមកនាំព្រះអង្គទៅស្ថានសួគ៌ ដើម្បីនឹងចាត់ព្រះអង្គឲ្យធ្វើសង្គ្រាមចំពោះទេវតានឹងអាវក្ស ។ ព្រះអង្គទ្រង់មានជោគជ័យក្នុងការសង្គ្រាមនោះ ហើយទ្រង់យាងចូលទៅសម្រាកព្រះកាយនូវព្រះរាជឧទ្យាន ។

ដល់ព្រះអង្គវិលត្រឡប់មកវិញ ព្រះអង្គយាងតាមអាស្រមបទនៃតាបសកស្សបៈ ដែលស្ថិតនៅក្នុងកំពូលមាស ហើយទ្រង់ឈប់ដើម្បីនឹងថ្វាយបង្គំនូវតាបសនេះ ។

នៅក្នុងអាស្រមបទ មានពួកឫសី ពួកស្រីតាបសិនី នាងទេវធីតា ពួកអាវក្សមាននាងសកុន្តលានឹងព្រះរាជបុត្រា, ព្រះអង្គម្ចាស់សវទមនៈ (Sarvadamana) នៅទីនោះដែរ ។

ព្រះបាទទុស្សន្តៈ ជាព្រះចក្រពត្តិ ព្រះរាជបុត្រាជាព្រះអង្គម្ចាស់នៃព្រៃព្រឹក្សា ។ សត្វទាំងអស់នៅក្នុងព្រៃស្រឡាញ់ព្រះអង្គម្ចាស់ហើយគោរពទ្រង់ពន់ពេក ។ នៅក្នុងព្រៃមានដើមពោធិ៍មួយធំ មានមែកស្លឹកទំហុំជុំវិញប្រាំពីរយោជន៍ ។ មានពស់វែកមួយសម្បើមអស្ចារ្យ ស្ថិតនៅក្រោមដើមពោធិ៍នោះរាល់យប់ថ្ងៃ: គឺនៅទីនេះឯងដែលព្រះអង្គម្ចាស់ប្រមូលសេនាទ្រង់មកធ្វើសន្និបាត ។

ពេលបុត្តណ្ណាសម័យ ដំរីបានយកព្រះអង្គម្ចាស់ដាក់លើក្បាល ទៅឯមាត់ស្ទឹង · នៅទីនោះវាយកប្រមោយស្រោចទឹកថ្វាយ ហើយយកទ្រង់មកឲ្យគង់លើខ្នងពស់ធំនោះ ដែលជាភុជបល្លង្ក ។ រួចពស់វែកនោះបានបើកពពារបាំងព្រះអង្គម្ចាស់ពីលើ ដូចជាព្រះខ្លស់ហើយនៅសងខាងមានដំរីពីរ បានយកស្លឹកឈូកធ្វើផ្លិតបក់ថ្វាយ ។

សត្វខ្លាឃ្មុំជានាយកវេជ្ជមន្ត្រីនៃព្រះអង្គម្ចាស់ ! សត្វរាជសីហ៍ជាមេទ័ព សត្វខ្លាជាសេនាព្រះអង្គ ហើយសត្វស្វានធ្វើអ្វី? សត្វស្វានធ្វើជានាយកក្រុមព្រះនគរបាល ។

មានតក្កមួយ គឺបក្សាសេកបានក្រាបទូលនូវរឿងរ៉ាវជាច្រើនថ្វាយព្រះអង្គម្ចាស់ សេកនោះលេងជាមួយនឹងកូនបក្សានៅក្នុងសំបុក, វាអង្គុយជិតកូនខ្លានៅក្នុងរូង ។ គ្មានសត្វណាធ្វើបាបបានទេ, សត្វទាំងអស់គោរពសេកនោះ ហើយមានចិត្តខ្លាចខ្លះដែរ ។

✣

✣ ✣

ព្រះបិតានិងព្រះរាជបុត្រ

កាលណាព្រះចក្រពត្តិទ្រង់យាងចូលទៅក្នុងព្រៃ ព្រះអង្គម្ចាស់កំពុងក្រសាលលេងនឹងកូនរាជសីហ៍, ព្រះអង្គម្ចាស់បានយកព្រះអង្គុលីទៅដាក់ក្នុងមាត់កូនរាជសីហ៍ រាប់ចំនួនធ្មេញគ្រះលេងកំសាន្ត ទាញរោមកវា ។

ពួកតាបសីភ័យខ្លាច ចង់ទាញព្រះអង្គម្ចាស់ចេញពីកូនរាជសីហ៍, ដើម្បីឲ្យព្រះអង្គម្ចាស់ឈប់លែងលេងនឹងរាជសីហ៍. នាងទាំងនោះបាន យកនូវក្អោកធ្វើពីដីមកថ្វាយ ទូកធ្វើពីសំបកឈើ វត្ថុលេងជាច្រើន តែព្រះអង្គម្ចាស់ មិនបានទ្រង់ព្រះសណ្ដាប់ នាងទាំងនោះឡើយ ។

ក្នុងពេលនោះ ព្រះចក្រពត្តិស្ដេចយាងមកដល់ ។ ព្រះអង្គ ទ្រង់ទាញកូនរាជសីហ៍ ចេញពីព្រះអង្គម្ចាស់ ទ្រង់បីព្រះអង្គម្ចាស់ ៗ ទៅ ជាមានព្រះទ័យសុខស្រួលនៅស្ងៀមទៅវិញ ។ ដោយព្រះចក្រពត្តិ មានព្រះទ័យជ្រះថ្លារីករាយជាយ៉ាងក្រៃលែង ក្នុងពេលដែលព្រះអង្គបាន បីព្រះអង្គម្ចាស់ ៗ ព្រះអង្គទ្រង់មិនបានជ្រាបថាព្រះអង្គម្ចាស់នោះ ជា រាជបុត្ររបស់ទ្រង់សោះឡើយ ទ្រង់បានសួរទៅព្រះអង្គវិញ ដោយ ព្រះទ័យឆ្ងល់ថា: “ ម្ដេចក៏ចិត្តអញស្រឡាញ់កូនអ្នកដទៃដូចនេះ ? ម្ដេចកូនដែលផ្ដេកនៅលើដើមទ្រូងអញធ្វើចិត្តរំជួលជាខ្លាំងដូចនេះ ” ។

ក្នុងពេលនោះស្រាប់តែនាងសកុន្ដលាមកដល់, នាងខំរកកូននាង នាងបានហៅកូន ស្រាប់តែកូននោះនៅលើព្រះហស្ដព្រះចក្រពត្តិ ... នាងបានចូលទៅជិតតាបសី ហើយព្រះបាទទុស្សន្តៈទ្រង់ក៏បានស្គាល់ នូវនាងសកុន្ដលា ។

ស្ដេចទ្រង់អង្វរនាង សូមទោសនាង, ហើយនាងសកុន្ដលា ពុំ មានក្រាបទូលតបអ្វីទៅព្រះអង្គវិញឡើយ ស្រាប់តែនាងចូលទៅសម្ងំ

ក្នុងព្រះហស្តព្រះអង្គ ដូចកាលពីដើមនាងធ្លាប់ធ្វើអកប្បកិរិយា នៅគុម្ពោតផ្កា.....។

✕
✕ ✕

## ការវិលត្រឡប់នៅអាស្រម

បណ្ដាសាតាបសទុរវាសៈ ផុតអំណាចជាអវសាន ។ ព្រះបាទទុស្មន្តៈទ្រង់បានធ្វើព្រះរាជសមរស នឹងនាងសកុន្តលាជាថ្មី ។

ដល់ថ្វាយបង្គំលាតាបសកស្សប (Kaçyapa) នឹងនាងអទិតី (aditi) ជាកិរិយារួចហើយ ទ្រង់ស្ដេចយាងត្រឡប់មកកាន់ព្រះរាជនិវេសនដ្ឋាន យកទាំងព្រះអគ្គមហេសី នឹងព្រះរាជបុត្រាមកផង ។

ព្រះចក្រពត្តិទ្រង់សោយរាជ្យជាសុខក្សេមក្សាន្ត ជាច្រើនវស្សា ហើយព្រះអង្គបានប្រគល់ព្រះរាជអាណាចក្រ ទៅព្រះរាជបុត្រគ្រប់គ្រងតព្រះរាជវង្ស ហើយទ្រង់ស្ដេចយាងជាមួយនឹងព្រះអគ្គមហេសី ទៅកាន់អាស្រមបទនៃតាបសកាមទេព ។

ព្រះនាងទ្រង់បានជួបនូវមិត្តនីទាំងពីរនាក់កូនក្ដាន់ញី បុប្ផាក្រជាតិ...

ព្រះនាងសកុន្តលានឹងព្រះចក្រពត្តិ ទ្រង់គង់នៅសុខសប្បាយជាមួយនឹងពួកតាបសៈ នឹងតាបសី លុះដល់ក្ស័យព្រះជន្ម ។

ចប់

# បញ្ជីសៀវភៅដែលបានបោះពុម្ពហើយ
# និងបម្រុងបោះទៅអនាគត

១– សុភាសិតបារាំងតែងជាពាក្យកាព្យភាគ ១

២– ” ២

៣– សកុន្តលា

៤– មហាត្មៈគន្ធី

៥– ស៊ុន-យាត-សេង

## បម្រុងនឹងបោះតទៅ

១– ខមប្កខ្មែរ ភាគ ១-២-៣-៤

២– នាលៈនឹងទមយន្តី (នាងស្រី-សារិះយ៉ាន់តែង)

៣– ប្រវត្តិលោកទ្រូមែន

៤– ដំណើរប្លែកអស្ចារ្យនៃលោក ក៉-សូ-ប៊ិ.យូ-យេ

៥– ប៉ាវិបន៉ា

៦– រឿងកូនប្រុសឆ្លើពីទងជាតិ

៧– សាវិតារ ខេត្តបាត់ដំបង

៨– នានាកាព្យគតិ ភាគទី ១-២-៣

៩– ពុទ្ធសាសនាប្រវត្តិ

រោងពុម្ពខ្មែរ